# កម្មវិធីសិក្សាជាន់ខ្ពស់នៃ អាយស៊ីធី ពិសេស
# សំរាប់ថ្នាក់ដឹកនាំក្នុងជួររដ្ឋាភិបាល

## មេរៀនទី ៧

## ទ្រឹស្តីនិងការអនុវត្តនៅក្នុងការគ្រប់គ្រងគម្រោងបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា( ICT )

Maria Juanita R. Macapagal and John J.Macasio

APCICT មជ្ឈមណ្ឌលហ្វឹកហ្វឺន អាស៊ី និង ប៉ាស៊ីហ្វិច សំរាប់វិស័យ បច្ចេកវិទ្យា
ព័ត៌មាន និង គមនាគមន៍ សំរាប់ការអភិវឌ្ឍន៍

**កម្មវិធីសិក្សាជាន់ខ្ពស់នៃ អាយស៊ីធី សំខាន់ សំរាប់ថ្នាក់ដឹកនាំក្នុងជួរ រដ្ឋាភិបាលបន្ត**

## មេរៀន ទី ៧: ទ្រឹស្តីនិងការអនុវត្តក្នុងការគ្រប់គ្រងគម្រោងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

អត្ថបទនេះគឺត្រូវបានផ្សព្វផ្សាយក្រោមអាជ្ញាប័ណ្ណរបស់ Creative Common Attribute ជំនាន់ ៣.០ ។ ដើម្បីស្វែងយល់អំពីច្បាប់របស់អាជ្ញាប័ណ្ណនេះ សូមចូរទៅកាន់ គេហទំព័រ http://creativecommands.org/ licenses/by/3.0 ។

មតិយោបល់ ទិន្នន័យ និង ការវាយតំលៃ ដែលមាននៅក្នុងការផ្សព្វផ្សាយនេះ គឺជាការទទួលខុសត្រូវរបស់អ្នកនិពន្ធ និងមិនមែនជាវាចារណាកថាដែលឆ្លុះបញ្ចាំងពីទស្សនៈ ឬ ការទទួលខុសត្រូវណាមួយ របស់អង្គការសហប្រជាជាតិឡើយ ។

ឧបករណ៍ដែលត្រូវបានប្រើប្រាស់សំរាប់ការរៀបចំ និង ការធ្វើបទបង្ហាញនៅក្នុង ការបោះពុម្ពផ្សាយនេះ នឹង មិនឆ្លុះបញ្ចាំងលើគំនិតយោបល់ណាមួយដែលជាប់ពាក់ ព័ន្ធនឹងទស្សនៈរបស់រដ្ឋលេខាធិការនៃអង្គការ សហប្រជាជាតិ សិទ្ធិស្របច្បាប់របស់ ប្រទេស ដែនដី ក្រុងឬតំបន់ ឬក៏ការកំណត់នៃដែនសីមាណាមួយឡើយ ។

ការប្រើប្រាស់នៃឈ្មោះក្រុមហ៊ុន ឬ ផលិតផលឧស្សាហកម្មណាមួយនៅក្នុងការ ផ្សព្វផ្សាយនេះ ក៏មិន មែនជាតួលេខរបស់អង្គការសហប្រជាជាតិដែរ ។

មជ្ឈមណ្ឌលហ្វឹកហ្វឺន អាស៊ី និង ប៉ាស៊ីហ្វិច
នៃអង្គការសហប្រជាជាតិ សំរាប់វិស័យ បច្ចេកវិទ្យា
ព័ត៌មានវិទ្យា និង គមនាគមន៍សំរាប់ការអភិវឌ្ឍ (UN-APCICT)
Bonbudong, 3rd Floor Songdo Techno Park
7-50 Songdo-dong, Yeonsu-gu, Incheon City
Republic of Korea

ទូរស័ព្ទ: +82 32 245 1700-02
ទូរសា: +82 32 245 7712

អ៊ីម៉ែលៈ info@unapcict.org
http://www.unapcict.org
រក្សាសិទ្ធ UN-APCICT 2009
ISBN: 978-89-955886-1-1 [94560]
រៀបចំ និង រចនាដោយៈ Sccandinavian Publishing Co., Ltd. និង studio triangle
បោះពុម្ពនៅក្នុងៈ សាធារណរដ្ឋកូរ៉េ

# បុព្វកថា

សតវត្សទី ២១ គឺបានលេចចេញយ៉ាងច្បាស់តាមរយៈការរីកចម្រើននៃផ្នែកទំនាក់ទំនង់ គ្នាក្នុងចំណោមប្រជាជន នៅក្នុងសាកលលោកនេះ វាគឺជាពិភពលោកមួយដែលឱកាស កំពុងបើកចំហរសំរាប់ប្រជាជនរាប់លាននាក់ ធ្វើការទាក់ទងគ្នាដោយឆ្លងកាត់បច្ចេកវិទ្យាថ្មីជាច្រើន, ការរីកដុះដាល់នៅការទទួលបានពត៌មាននិងចំណេះដឹងចាំបាច់ ដទៃទៀត បានធ្វើឲ្យប្រសើរឡើងគួរឲ្យកត់សម្គាល់សំរាប់ជីវភាពរស់នៅរបស់ប្រជាជននិង ជួយកាត់បន្ថយភាពក្រីក្រផងដែរ ។ រឿងនេះត្រឹមតែអាចទៅរួច ប្រសិនបើការរីកចម្រើននៃផ្នែកទាក់ទងគ្នាគឺត្រូវបានគេឲ្យតម្លៃ ភាពប្តេជ្ញាចិត្ត និង សាមគ្គីភាព ដោយការដាក់បញ្ចូលទាំងការការពារនៃការអភិវឌ្ឍទាំងនោះ ដែលត្រូវ ធ្វើឡើងសំរាប់ មនុស្សគ្រប់គ្នា ។

នៅក្នុងរយៈកាលថ្មីៗនេះ តំបន់អាស៊ីនិងប៉ាស៊ីហ្វិច គឺជាតំបន់ដ៏វិសេសធំបំផុតមួយ នៅពេលដែលតំបន់នេះបានប្រើប្រាស់នៅ បច្ចេកវិទ្យា ពត៌មាន និង គមនាគមន៍ (អាយស៊ីធីអេស) ។ យោងតាមសហគមគមនាគមន៍អន្តរជាតិ តំបន់អាស៊ីនិងប៉ាស៊ីហ្វិចគឺមានផ្ទះ ដែលប្រើប្រាស់ទូរស័ព្ទលើតុច្រើនជាង ពីររយកោដិ និង អ្នក ប្រើប្រាស់ទូរស័ព្ទដៃចំនួន ១.៤ រយកោដិ ។ បើគិតចំពោះតែប្រទេសចិននិងឥណ្ឌានោះគឺស្មើនឹងពាក់កណ្តាល នៃការ ប្រើប្រាស់ ទូរស័ព្ទនៅក្នុងពិភពលោក សម្រាប់ទិន្នន័យគិតត្រឹមឆ្នាំ២០០៨។ តំបន់អាស៊ីនិងប៉ាស៊ីហ្វិចផងដែរ គឺតំណាងឲ្យ ៤០ ភាគរយ នៃអ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធើរណេតរបស់ពិភពលោក និងជាទីផ្សារនៃការប្រើប្រាស់ រលកអាកាសផ្សព្វផ្សាយដ៏ធំបំផុត នៅក្នុងពិភពលោក គឺ ស្មើនឹង ចំនួន ៣៩ ភាគរយ នៃការចែកចាយសរុបទាំងមូល។

ការជំទាស់ទៅនឹងប្រវត្តិនៃការរីកចម្រើនជឿនលឿនយ៉ាងរហ័សនៃបច្ចេកវិទ្យានេះ មានមតិភាគច្រើនមានមន្ទិលសង្ស័យថា ប្រសិនបើការបែកចែករលកសញ្ញាត្រូវវិនាសបាត់បង់ នឹងទៅជាយ៉ាងម៉េច។ ជាអកុសល ការឆ្លើយ តបនឹងសំនួរនេះនៅមិនទាន់មាននៅឡើយ។ សូម្បីជារយៈពេល ៥ ឆ្នាំហើយបន្ទាប់ពីជំនួបកំពូលពិភពលោកទៅលើ វិស័យពត៌មានវិទ្យា (The World Summit on The Information Society (ដាប់ប៊ែយូអេសអាយអេស)) ត្រូវ បានធ្វើឡើងនៅក្នុង ជេនណេវ៉ា(Geneva) នៅក្នុងឆ្នាំ២០០៣ និងថ្មីបើរាល់ការរកឃើញនៃបច្ចេកវិទ្យាដ៏ធំសម្បើម ព្រមទាំងការប្តេជ្ញាចិត្តនៃអ្នកបំរើការងារដល់សំខាន់ៗក្នុងតំបន់ក៏ដោយ ក៏ដំណើរការគមនាគមជាមូលដ្ឋាននៅតែបន្តគម្លាតដ៏ឆ្ងាយពីចំនួនមនុស្សភាគច្រើន ជាពិសេសសំរាប់ជនក្រីក្រ ។

ច្រើនជាង ២៥ ប្រទេសនៃតំបន់មួយ ភាគច្រើនជាប្រទេសកំពុងអភិវឌ្ឍន៍នៃដែនកោះតូចៗ និង ប្រទេសកំពុងអភិវឌ្ឍន៍ដែលមិនមានព្រំដែនជាប់នឹងឆ្នេរសមុទ្រ មានចំនួនអ្នក ប្រើប្រាស់ប្រព័ន្ធអ៊ីនធើរណេត

តិចជាង ១០ នាក់ក្នុងចំណោមមនុស្ស ១០០ នាក់ ដែលភាគច្រើនជាអ្នករស់នៅក្នុងទីក្រុងធំៗនៃប្រទេសទាំងនោះ ផ្ទុយទៅវិញ កំឡុងពេលដែលប្រទេសជឿនលឿនដែលស្ថិតនៅក្នុងតំបន់នោះដែរ មានអត្រានៃអ្នកប្រើប្រាស់ប្រព័ន្ធ អ៊ីនធើរណេត ៨០ នាក់ ក្នុងចំណោមមនុស្ស ១០០ នាក់ ។ រលកនៃការផ្សាយរបស់ប្រទេសរីកចំរើន និង ប្រទេសកំពុងអភិវឌ្ឍន៍ គឺមានភាពខុសគ្នាយ៉ាងសម្បើម ។

ដើម្បីភ្ជាប់ការបែងចែកនៃរលកសញ្ញា និង ការធ្វើឲ្យលេចឡើងនៅ អាយស៊ីធី យ៉ាងមានសក្តានុពលមួយនោះ ទាំងទៅក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចវិទ្យានៅក្នុងតំបន់ រួមទាំងអ្នកបង្កើតច្បាប់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍នោះ ពួកយើងត្រូវការបង្កើតនៅ អទិភាពឲ្យបានច្រើន, អនុម័តនៅគោលនយោបាយមួយចំនួន, រៀបចំយ៉ាងជាក់លាក់នៅ ច្បាប់ និង និយតកររគម្រោង, ផ្តល់ប្រាក់មូលនិធិ, និងជួយសម្រួលក្នុងភាពជាដៃគូផ្សេងៗជាច្រើនទៀត ដើម្បីជំរុញ វិស័យ ឧស្សាហកម្ម អាយស៊ីធី ព្រមទាំងធ្វើការអភិវឌ្ឍនៅជំនាញ អាយស៊ីធី ឲ្យដល់ចំណោមប្រជាជនរបស់ពួកគេ ។

ដូចដែលគម្រោងសកម្មភាពមួយ (The Plan of Action) នៃ ដាប់ប៊ែយូអេសអាយអេស(WSIS) បានថ្លែងថា “...រាល់បុគ្គលគួរតែទទួលបាន ឱកាសក្នុងការទទួលយកនៅជំនាញចាំបាច់ណាមួយ រួមទាំងចំណេះដឹង ដើម្បីយល់ដឹង ដើម្បីចូលរួម និងដើម្បីទទួលបានប្រយោជន៍ពីសង្គមពត៌មានវិទ្យា រួមទាំងចំណេះដឹង ផ្នែកសេដ្ឋកិច្ច។” នៅទីបញ្ចប់ គម្រោងសកម្មភាពនេះ បានអំពាវនាវឲ្យមានការសហការនៅក្នុងតំបន់និងជាអន្តរជាតិសំរាប់វិស័យ នៃការកសាង សមត្ថភាព ដោយធ្វើការសង្កត់ធ្ងន់ ទៅលើការបង្កើតការប្រមូលផ្តុំយ៉ាងធំមួយសំរាប់អ្នកមាន វិជ្ជាជីវៈនិងជំនាញការ ខាង អាយស៊ីធី អោយបានច្រើន ។

ជាការឆ្លើយតបនឹងការអំពាវនាវនេះ ភីស៊ីអាយស៊ីធី(PCICT) បានធ្វើការអភិវឌ្ឍនៅ អាយស៊ីធី ដ៏ធំទូលាយមួយ នេះសំរាប់ ការអភិវឌ្ឍន៍នៅកម្មវិធីហ្វឹកហ្វឺនដែលមានឈ្មោះថា *កម្មវិធីសិក្សាជាន់ខ្ពស់នៃ អាយស៊ីធី ពិសេស សំរាប់ ថ្នាក់ដឹកនាំក្នុងជួររដ្ឋាភិបាល* ដែលក្នុងពេលឥឡូវនេះ មានប្រាំបីវគ្គ ផ្សេងៗពីគ្នា ប៉ុន្តែវគ្គនីមួយៗមានទំនាក់ទំនងគ្នា ដោយមានគោលបំណងចែករំលែក ចំណេះដឹងរួមទាំងជំនាញពិសេស ដែលនឹងជួយអ្នកបង្កើតច្បាប់ ឲ្យមានចិត្តនឹង ប្រើនូវចំណេះដឹង ដែលទទួលបានពី អាយស៊ីធី ប្រកបដោយប្រសិទ្ធិភាព ។

អេភីស៊ីអាយស៊ីធី(APCICT) គឺជាវិទ្យាស្ថានមួយក្នុងចំណោមវិទ្យាស្ថាន ៥ របស់គណកម្មាធិការសង្គមនិងសេដ្ឋកិច្ច នៃ អង្គការសហប្រជាជាតិដែលប្រចាំនៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិច (the United Nations Economic and Social Commission of Asia and the Pacific (អ៊ីអេសស៊ីអេភី(ESCAP)) ។ អ៊ីអេសស៊ីអេភី ជំរុញឲ្យមានការគាំពារនិង ការដាក់បញ្ចូលការអភិវឌ្ឍផ្នែក សេដ្ឋកិច្ចសង្គម ទៅក្នុងអាស៊ីនិងប៉ាស៊ីហ្វិច តាមរយៈការវិភាគ, ការងារសាមញ្ញៗ, ការកសាងសមត្ថភាព, ការសហកាក្នុងតំបន់, រួមទាំងការចែករំលែកនៅចំណេះដឹងក្នុងភាពជាដៃគូក្នុងស្រុក និង បណ្តាភាគហ៊ុនផ្សេងៗទៀត,

អ៊ុអេសស៊ុអេភី, តាមរយៈ អេភីស៊ីអាយស៊ីធី គឺបាន ទទួលយកការផ្តត់ផ្គង់ចំពោះ ការប្រើប្រាស់ សេចក្តីត្រូវការ និង ការបកប្រែនៃមេរៀនរបស់ អាខេឌីមិច (Academic) នេះនៅក្នុងប្រទេស ផ្សេងៗពីគ្នាជាច្រើន ព្រមទាំងការចែកចាយយ៉ាងទៀងទាត់របស់ពួកគេដែលធ្វើឡើងជាបន្តបន្ទាប់ តាមរយៈសិក្ខាសាលាថ្នាក់ជាតិនិងតំបន់ សំរាប់មន្ត្រីជាន់ខ្ពស់ និង មន្ត្រីថ្នាក់កណ្តាល រួមទាំងទិសដៅផ្សេងទៀតដែលទាក់ទងនឹង ការកសាងសមត្ថភាពរួម ព្រមទាំងទទួលបានមកវិញនូវចំណេះដឹង ហើយត្រូវបានគេបកប្រែដាក់ បញ្ចូលបន្ថែម ដើម្បីបង្កើនការយល់ដឹងនៃសារៈប្រយោជន៍ អាយស៊ីធី និង សកម្មជាក់ស្តែងឆ្ពោះទៅរកការ អភិវឌ្ឍទិសដៅជាច្រើន ។

Noeleen Heyzer

អនុរដ្ឋលេខាធិការនៃអង្គការសហប្រជាជាតិ
និង លេខាធិការប្រតិបត្តិនៃ អ៊ីអេសស៊ីអេភី

# អារម្ភកថា

ដំណើរការនៅក្នុងការវិវត្តនៃ *កម្មវិធីសិក្សាជាន់ខ្ពស់នៃ អាយស៊ីធី ពិសេសសំរាប់ថ្នាក់ដឹកនាំក្នុងជួរ រដ្ឋាភិបាលសម្រាប់វគ្គ បន្ត* នេះ ពិតជាបានបង្ហាញនៅការផុសឡើងនៅបទពិសោធន៍ថ្មីៗ ។ The Academy មិនត្រឹមតែបំពេញបន្ថែមទៅ ក្នុងការកសាងសមត្ថភាពនៃការយល់ដឹងអំពី អាយស៊ីធី ប៉ុន្តែថែមទាំងបានត្រួសត្រាផ្លូវថ្មីមួយសំរាប់ការអភិវឌ្ឍន៍នៅកម្មវិធីសិក្សា (តាមរយៈការចូលរួមរបស់អ្នកសិក្សា និងភាពជាម្ចាស់នៃការអនុវត្ត) ។

The Academy គឺជាកម្មវិធីដល់ល្អបំផុតរបស់ អេភីស៊ីអាយស៊ីធី, ដែលបានធ្វើការអភិវឌ្ឍន៍ពឹងផ្អែកលើៈ លទ្ធផល នៃការស្ទង់មតិដ៏ចាំបាច់ជាច្រើនប្រកបដោយភាពទូលំទូលាយ ដែលធ្វើឡើងជាមួយចំនួនប្រទេសច្រើនជាង ២០ នៅក្នុងតំបន់ រួមទាំងទទួលការប្រឹក្សាយោបល់ពីមន្ត្រីរដ្ឋាភិបាលជាច្រើនរូប, សមាជិកជាច្រើននៃសហគមន៍អភិវឌ្ឍន៍អន្តរជាតិ, កម្មវិធីសិក្សានិងអ្នកអប់រំជាច្រើនរូប, ធ្វើការស្រាវជ្រាវនិងវិភាគយ៉ាងស៊ីជំរៅអំពីភាពខ្លាំង និង ភាពខ្សោយ ចំពោះឧបករណ៍សម្រាប់ការហ្វឹកហ្វឺនដែលមានស្រាប់, ប្រតិកម្មតបរបស់អ្នកចូលរួមសិក្ខាសាលារបស់ អេភីស៊ីអាយស៊ីធី ដែលបានរៀបចំឡើងជាបន្តបន្ទាប់សម្រាប់ថ្នាក់តំបន់ និងអនុតំបន់ទៅលើអត្ថប្រយោជន៍និងភាពជាប់ទាក់ទងគ្នា ពីវគ្គមួយទៅវគ្គមួយ រួមទាំងយុទ្ធសាស្ត្រហ្វឹកហ្វឺនយ៉ាងសមរម្យមួយ, និងមានភាពប្រាកដនិយមនៅក្នុងការរំលឹក ឡើងវិញអំពីវគ្គទាំងនោះ ដោយមានការដឹកនាំពីអ្នកជំនាញជាច្រើនរូបនៅក្នុងវគ្គសិក្សា សម្រាប់ការអភិវឌ្ឍវិស័យ អាយស៊ីធី ។ សិក្ខាសាលារបស់ The Academy ត្រូវបានធ្វើឡើង តាមតំបន់ដែលបានផ្តល់ឱកាសដែលមិនអាចកាត់ថ្លៃ បានក្នុងការផ្លាស់ប្តូរបទពិសោធន៍ និងចំណេះដឹងក្នុងចំណោមអ្នកចូលរួមពីប្រទេសផ្សេងៗ សិក្ខាសាលានេះដែលបានបង្កើតនៅ Academy Alumni នឹងដើរតួយ៉ាងសំខាន់ក្នុងការធ្វើឲ្យលេចចេញជារូបរាងនៅមេរៀនជាបន្តបន្ទាប់ ។

ការដាក់បង្ហាញចេញដំបូងនៅវគ្គសិក្សាទាំងប្រាំបី សម្គាល់ឃើញថាជាការចាប់ផ្តើមសម្រាប់ដំណើរការដ៏ជោគជ័យ ដែលជាភាពខ្លាំងនៃដៃគូដែលមានស្រាប់ និងការកសាងភាពថ្មីផ្សេងមួយទៀតដើម្បីអភិវឌ្ឍនៅក្នុងការធ្វើឲ្យសម្រេច នៅគោលនយោបាយរបស់ អាយស៊ីធីឌី កាត់តាមតំបន់ ។ អេភីស៊ីអាយស៊ីធីគឺបានប្តេជ្ញាចិត្តជាអ្នកផ្តល់ ក្នុងការផ្គត់ផ្គង់ផ្នែកបច្ចេកទេសនៅក្នុងការផ្សព្វផ្សាយពី National Academies ពីព្រោះថាការឆ្ពោះទៅមុខយ៉ាង សំខាន់របស់វា គឺការធានាថា The Academy គឺចាប់បានរាល់ការសម្រេចនៅគោលនយោបាយរបស់ខ្លួន ។ អេភីស៊ីអាយស៊ីធី ផងដែរបាននឹងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយវិទ្យាស្ថានហ្វឹកហ្វឺនរបស់ជាតិនិងតំបន់មួយចំនួន ដែលមានទំនាក់ទំនងជាមួយការគ្រប់គ្រង

ថ្នាក់កណ្ដាល, ការគ្រប់គ្រងរបស់រដ្ឋ និងការគ្រប់គ្រង់តាមលំដាប់ថ្នាក់ ប្រចាំតំបន់ ដើម្បីធ្វើឲ្យប្រសើរឡើងនៅសមត្ថភាពរបស់ពួកគេក្នុងការឆ្លើយតបនៅតំរូវការ ការបកប្រែ និង ការប្រគល់ ឲ្យនៅមេរៀននីមួយៗរបស់ Academy ព្រមទាំងធ្វើវាទៅជាសេចក្ដីត្រូវការ និងជាអទិភាពដំបូងសម្រាប់រដ្ឋ ។

ច្រើនជាងនេះទៅទៀត អេភីស៊ីអាយស៊ីធី កំពុងតែជួលនៅប៉ុស្តិ៍ជាច្រើនសម្រាប់ការខិតទៅរកការជានាមួយថា ខ្លឹមសារមេរៀនរបស់ Academy បានទៅដល់អ្នកមើលក្នុងលក្ខណៈយ៉ាង ទូលំទូលាយនៅក្នុងតំបន់មួយ ។ ក្រៅពីការផ្ដល់ឲ្យជាលក្ខណៈផ្ទាល់របស់ Academy តាមរយៈកម្មវិធីសិក្សាជាច្រើនរបស់ជាតិនិងតំបន់ Academy ផងដែលផ្ដល់ឲ្យជា លក្ខណៈ the APCICT Virtual Academy (អេវីអា(AVA)), គឺជាទម្រង់នៃការសិក្សាពីចម្ងាយ តាមប្រព័ន្ធ Online របស់ Academy, ដែលត្រូវបង្កើតឡើងដើម្បីឲ្យអ្នកសិក្សាទទួល បានចំណេះដឹងពីកន្លែង របស់ខ្លួនគេផ្ទាល់ ។ AVA ជានាថាវគ្គនីមួយៗរបស់ Academy រួមទាំងឧបករណ៍ដទៃទៀត ដូចជា ផ្ទាំងបញ្ចាំងអំពីបទបង្ហាញនៃមេរៀន និង ករណីសិក្សាដទៃទៀត គឺមានភាពងាយស្រួលក្នុងការទាញយកមកពីប្រព័ន្ធអ៊ីនធើរណិត, ការយកមកប្រើម្តងទៀត, ឆ្លើយតបតាមតំរូវការនិងឋានបរិច្ឆេទ រួមទាំងការប្រើប្រាស់នៅលើមុខងារផ្សេងៗទៀត រួមមាន ការបង្រៀនជា មូលដ្ឋានគ្រឹះ, ការសិក្សាស្វែងយល់ទៅលើការគ្រប់គ្រងឧបករណ៍ផ្សេងៗ, ខ្លឹមសារមេរៀនស្តីអំពីការអភិវឌ្ឍន៍ទៅលើ ឧបករណ៍មួយចំនួន ព្រមទាំងវិញ្ញាបណ្ណប័ត្រ។

ជាអាទិ៍ការបង្កើតនៅវគ្គទាំងប្រាំបីរបស់ Academy និងការផ្ដល់ឲ្យពួកគេតាមរយៈសិក្ខាសាលាស្ដីពី Academy របស់ថ្នាក់ជាតិ, ថ្នាក់តំបន់និងអនុតំបន់ និងមិនអាចប្រព្រឹត្តទៅបានប្រសិនបើគ្មានការប្ដេជ្ញាចិត្តការចង្អុលបង្ហាញនិង ពីអ្នកចូលរួមយ៉ាងសកម្មរបស់ បុគ្គលៗម្នាក់ ឬពីអង្គការជាច្រើននោះទេ ។ ខ្ញុំសូមយកឱកាសនេះ សំដែងនៅសមានចិត្ត សម្រាប់ការប្រឹងប្រែង ព្រមទាំងការសម្រេចនូវស្នាដៃនៃ Academy Alumni ដោយមានការសហការពីក្រសួង រដ្ឋាភិបាល, វិទ្យាស្ថានហ្វឹកហ្វឺន, ព្រមទាំងអង្គការជាតិនិងអង្គការ ប្រចាំតំបន់ជាច្រើនដែលបានចូលរួមក្នុងសិក្ខាសាលា Academy ។ ពួកគេមិនត្រឹមតែ ផ្ដល់នៅទស្សនៈដ៏មានតំលៃជាច្រើន ដើម្បីដាក់បញ្ចូលទៅក្នុងវគ្គនីមួយៗ ប៉ុន្តែថែមទាំងដើរតួយ៉ាងសំខាន់ជាច្រើនទៀត ដោយពួកគេបានក្លាយជាអ្នកជួយគាំទ្រ Academy នៅក្នុងប្រទេសពួកគេដែលឲ្យជា លទ្ធផលសម្រាប់ការឃោគយល់គ្នាជាលក្ខណៈផ្លូវការ រវាង អេភីស៊ីអាយស៊ីធី ជាមួយវិទ្យាស្ថានរបស់ជាតិ និងតំបន់មួយចំនួន ក្នុងការផ្ដល់នៅការឆ្លើយតបតាមតំរូវការ និងការប្រគល់ឲ្យនៅមុខវិជ្ជារបស់ Academy សម្រាប់ប្រទេសទាំងនោះ យ៉ាងទៀងទាត់ ។

ខ្ញុំសូមសម្ដែងនៅសមានចិត្តជាការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត សម្រាប់ការខិតខំប្រឹងប្រែងក្នុងការចូលរួមពីបុគ្គលដែលប្រកបដោយគតិបណ្ឌិតជាច្រើនរូប ក្នុងការបង្កើតនៅដំណើរការប្រតិបត្តិដ៏អស្ចារ្យមួយនេះឲ្យប្រព្រឹត្តទៅ បាន ដែលមានដូចជា លោក Shahid Akhtar, ទីប្រឹក្សាគម្រោងនៃ *The*

*Academy*, Patricia Arinto, Christine Apikul, Publications Manager, និងរាល់អ្នកនិពន្ធ *Academy,* និងក្រុម អេភីស៊ីអាយស៊ីធី ។

ខ្ញុំសង្ឃឹមយ៉ាងស្មោះស្ម័គ្រថា *Academy* មួយនេះនឹងជួយប្រទេសជាច្រើនឲ្យរួចផុតពីចន្លោះប្រហោងក្នុងការ បណ្តុះបណ្តាលធនធានមនុស្សផ្នែក អាយស៊ីធី, ដកចេញនៅភាពរាំងស្ទះក្នុងការទទួលយក អាយស៊ីធី មកប្រើប្រាស់ ដោយផ្ទាល់ខ្លួន ព្រមទាំងជួយជំរុញឲ្យមានការអនុវត្តន៍នៃវិស័យ អាយស៊ីធី ដើម្បីពន្លឿន ការអភិវឌ្ឍវិស័យសេដ្ឋកិច្ចសង្គម រួមទាំង ការសម្រេចបានស្នាដៃក្នុងគោលដៅរាប់លានផ្សេងទៀត។

Hyeun-Suk Rhee
ប្រធាន
UN-APCICT

# អំពីក្រុមមេរៀន

នៅក្នុងយុគសម័យនៃពត៌មានសព្វថ្ងៃ, ភាពងាយស្រួលក្នុងការទាញយកពត៌មាននិងកំពុង ធ្វើការផ្លាស់ប្តូរនៅលើ មធ្យោបាយ សម្រាប់ការរស់នៅ ការធ្វើការងារ និង ការកំសាន្ត របស់ពួកយើង ។ “digital economy” គឺត្រូវ បានគេស្គាល់ផងដែរថាជា “ចំណេះដឹងផ្នែក សេដ្ឋកិច្ច”, “សេដ្ឋកិច្ចបណ្តាញ” ឬ

“សេដ្ឋកិច្ចសម័យថ្មី”, ដែលត្រូវបាន ចង្អុលបង្ហាញដោយការផ្លាស់ប្ដូរពីការការផលិតនៅទំនិញទៅជាការបង្កើតនៅគំនិតជាច្រើន ។ ប្រសិនបើមិនដឹងនៅ ឡើយពីសារៈសំខាន់នៅការរីកចម្រើនក្នុងពេលបច្ចុប្បន្ននេះ ការគូសបញ្ជាក់អំពីការរីកចម្រើនមួយនេះនឹងបានដើរ តួនាទីយ៉ាងសំខាន់ប្រាប់ពីការរីកចម្រើននៃវិស័យបច្ចេកវិទ្យា ពត៌មាន និង គមនាគមន៍ (ICT) ទាំងនៅក្នុងវិស័យ សេដ្ឋកិច្ច ក៏ដូចជានៅក្នុងសង្គមទាំងមូលផងដែរ ។

ជារឿយៗ រដ្ឋាភិបាលនៅទូទាំងពិភពលោកបានធ្វើការគិតគូរយ៉ាងខ្លាំងទៅលើការអភិវឌ្ឍន៍វិស័យ ICTs (Information and Communication Technology for Development (ICTD)។ សម្រាប់រដ្ឋាភិបាលទាំងនេះ ICTD គឺមិនត្រឹម តែដើរតួនាទីអំពី ការអភិវឌ្ឍន៍វិស័យ ឬ ឧស្សាហកម្ម ICT ចំពោះតែសេដ្ឋកិច្ចប៉ុណ្ណោះ ប៉ុន្តែក៏សម្រាប់ការប្រើប្រាស់លើកត្តាផ្សេងៗទៀតផងដែរ នោះជាហេតុនាំឲ្យមានការលូតលាស់លើផ្នែក សេដ្ឋកិច្ច ក៏ដូចជាការលូតលាស់របស់សង្គមនិង នយោបាយ ។

ទោះបីយ៉ាងណាក៏ដោយ, ក្នុងចំណោមភាពពិបាកជាច្រើន ដែលរដ្ឋាភិបាលប្រឈមមុខ នៅក្នុងបង្កើតច្បាប់ ICT គឺថាអ្នកបង្កើតច្បាប់ជាញឹកញាប់គឺមិនស្គាល់ច្បាស់ជាមួយ បច្ចេកទេសណាមួយដែលពួកគេបាននឹងកំពុងបំពាក់សម្រាប់ការអភិវឌ្ឍន៍ប្រទេសនោះទេ ។ គ្មានបុគ្គលណាម្នាក់អាចធ្វើនៅអ្វីមួយផ្សេងទៀតដែលខ្លួនមិនបានដឹងអំពីវាបានឡើយ ដូច្នេះ អ្នកបង្កើតច្បាប់ទាំងនោះបានស្ថិតទៅម្ខាងពីការបង្កើតច្បាប់ ICT ។ ប៉ុន្តែការផ្តល់ភារកិច្ចនោះ ទៅឲ្យអ្នកបច្ចេកទេសគឺជា ការខុសឆ្គង ពីព្រោះជាញឹកញាប់អ្នកបច្ចេកទេសគឺមិនដឹងមុនពីការជាប់ទាក់ទិនគ្នានៃច្បាប់ ជាមួយនឹង បច្ចេកវិទ្យា ដែលពួកគេកំពុងតែអភិវឌ្ឍន៍និងកំពុងប្រើប្រាស់នោះទេ ។

មេរៀនបន្តនៃ *កម្មវិធីសិក្សាជាន់ខ្ពស់នៃ អាយស៊ីធី(ICT) ពិសេស សម្រាប់ថ្នាក់ដឹកនាំក្នុងជួររដ្ឋាភិបាល* ត្រូវបាន អភិវឌ្ឍន៍ឡើងដោយមជ្ឈមណ្ឌលហ្វឹកហ្វឺន អាស៊ីនិង ប៉ាស៊ីហ្វិចនៃអង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍវិស័យ បច្ចេកវិទ្យា ពត៌មាន និង គមនាគមន៍ (United Nations Asia and Pacific Training Centre for Information and Communication Technology for Development (UN-APCICT)) សម្រាប់ឲ្យ

១. អ្នកបង្កើតច្បាប់ប្រចាំប្រទេស និង កម្រិតអ្នកគ្រប់គ្រងតាមតំបន់ ដែលមានតួនាទីទទួលខុសត្រូវក្នុងការបង្កើត ច្បាប់ អាយស៊ីធី (ICT) ។

២. មន្ត្រីរដ្ឋាភិបាលដែលទទួលខុសត្រូវសម្រាប់ការអភិវឌ្ឍន៍និងមន្ត្រីដែលជាប់ពាក់ព័ន្ធ ទៅលើដំណើរការជាមូលដ្ឋានគ្រឹះរបស់ អាយស៊ីធី(ICT) នឹង

៣. អ្នកគ្រប់គ្រងផ្សេងៗទៀតក្នុងផ្នែកសាធារណ៍ដែលកំពុងស្វះស្វែងរកការជួលពី អាយស៊ីធី (ICT) សម្រាប់បម្រើលើគម្រោងនៃការគ្រប់គ្រងណាមួយ ។

មេរៀនបន្តនេះមានគោលបំនងដើម្បីអភិវឌ្ឍឲ្យថ្មឹកជាមួយបញ្ហាសំខាន់ៗជាច្រើន ដែលមានការទាក់ទងនឹង អាយស៊ីធី (ICT) ដែលបានមកទាំងពីច្បាប់ រួមទាំង ទស្សនវិស័យនៃបច្ចេកវិទ្យា។ គ្មានការប៉ុនប៉ងណាមួយក្នុងការអភិវឌ្ឍវិស័យ អាយស៊ីធី(ICT) ដែលដំណើរការដោយដៃ ប៉ុន្តែវាបែរជាផ្តល់នៅការយល់ដឹងដល់ល្អចំពោះសមត្ថភាពនៃបច្ចេកវិទ្យាថ្មីរបស់ប្រព័ន្ធឌីជីថល (Digital) ឬនៅកន្លែងណាដែលបច្ចេកវិទ្យាមានការនាំមុខគេ និងអ្វីដែលគូស បញ្ជាក់សម្រាប់ការ បង្កើតច្បាប់របស់ អាយស៊ីធី(ICT) ។ ប្រធានបទជាច្រើនក្នុងមេរៀនទាំងនេះ ត្រូវបានដឹងមកតាមរយៈការវិភាគពី សេចក្តីត្រូវការនានានៃវគ្គហ្វឹកហ្វឺន និង ការស្ទាបស្ទង់ពីឧបករណ៍ហ្វឹកហ្វឺនដទៃទៀតពីជុំវិញពិភពលោក ។

មេរៀនទាំងនេះត្រូវបានរៀបចំឡើងដូចជាមធ្យោបាយមួយ ដែលអាចត្រូវបានគេប្រើប្រាស់ ក្នុងការសិក្សាផ្ទាល់ខ្លួន ដោយអ្នកអានម្នាក់ៗ ឬក៏ជាប្រភពមួយនៅក្នុងកម្មវិធីសិក្សា ឬ សម្រាប់វគ្គហ្វឹកហ្វឺនណាមួយ ។ មេរៀនគឺមួយៗដាច់ ដោយឡែកពីគ្នា តែដូចជាត្រូវបានចងភ្ជាប់បញ្ចូលគ្នាតែមួយ រួមទាំងការខិតខំព្យាយាមធ្វើនៅមេរៀននីមួយៗនេះតភ្ជាប់គ្នា ទៅនឹងវិជ្ជានិពន្ធខ្លីៗ រួមទាំងបទពិភាក្សាមួយចំនួនដែលមាននៅក្នុងមេរៀនផ្សេងៗទៀតជាបន្តមក ។ គោលបំណង ក្នុងរយៈពេលវែងគឺការបង្កើតមេរៀនទាំងនោះឲ្យមានភាពជាប់ប្រទាក់គ្នា ដែលអាចត្រូវបានទទួលស្គាល់ជាផ្លូវការ ។

មេរៀននីមួយៗចាប់ផ្តើមជាមួយការប្រាប់ពីគោលបំណងនៃមេរៀននោះ និងទិសដៅនៃលទ្ធផលនៃការសិក្សា ដែលបានមកពីការប្រឆាំងតបតរបស់អ្នកអានចំពោះអ្វីដែលពួកគេបានសិក្សា ការធ្វើដូច្នោះអាចធ្វើឲ្យពួកគេប៉ាន់ប្រមាណបាននៅភាពរីកចម្រើនផ្ទាល់ខ្លួនរបស់ពួកគេ។ មាតិកាមេរៀនគឺត្រូវបានចែកចេញជាផ្នែកៗ ដែលរួមមានទាំងផ្នែក មេរៀន និង លំហាត់ ដើម្បីជាជំនួយឲ្យរឹតតែយល់ដឹងកាន់តែច្បាស់អំពីគន្លឹះសំខាន់ៗនៃមេរៀន ។ លំហាត់ ទាំងនោះ អាចធ្វើដោយអ្នកអានរៀងៗខ្លួន ឬ អាចដោះស្រាយជាលក្ខណៈជាក្រុមនៃអ្នកចូលរួមវគ្គហ្វឹកហ្វឺននោះ ។ ដើម្បីគូសបញ្ជាក់នៅទិដ្ឋភាពជាក់លាក់ទៅលើចំនុចនីមួយៗនោះ រូបភាព និង តារាង គឺត្រូវបានប្រើប្រាស់សម្រាប់ការលម្អិតខ្លឹមសារទាំងនោះ ។ ឯកសារយោង និង ប្រភពមួយចំនួនពីអ៊ីនធើរណិត គឺបានរាយជាបញ្ជីសម្រាប់អ្នកអានធ្វើការស្វែងរក ដើម្បីជាជំនួយបន្ថែមទៅលើការសិក្សានេះ ។

របៀបរៀបចំនៃ អាយស៊ីធីឌី(ICTD) គឺដូចជាមានលក្ខណៈផ្សេងៗពីគ្នា ដែលពេលខ្លះផ្នែក មេរៀន និង លំហាត់ អាចមានភាពផ្ទុយគ្នា ។ ករណីនេះគឺត្រូវបានរំពឹងថាមាននៅក្នុងការរៀបចំនេះ ។ ហើយករណីនេះ គឺគ្រាន់តែធ្វើឲ្យមានភាពភ្ញាក់ផ្អើល និង ប្រកបដោយភាពប្រកួតប្រជែងអំពីការផុសឡើងនៅរបៀបអប់រំថ្មីៗ និង ភាពប៉ិនប្រសប់របស់វា ដូចដែលរាល់ប្រទេស លើពិភពលោកទាំងអស់ ចាប់ផ្តើមព្យាយាមរុករកនៅសក្តានុពលនៃ អាយស៊ីធីអេស(ICTs) ដើម្បីប្រើប្រាស់សម្រាប់ការអភិវឌ្ឍន៍ដូច្នោះដែរ ។

គាំទ្រឲ្យមានការបោះពុម្ពនៅមេរៀន Academy បន្ទាប់ជាលក្ខណៈ សិក្សាពីចម្ងាយនៅលើ ប្រព័ន្ធអនឡាយន៍(Online) – the APCICT Virtual Academy (AVA – http://www.unapcict.org/academy) – ដែលមានលក្ខណៈដូចជា ការសិក្សាក្នុងបន្ទប់រៀនពិតៗ ដែលបទបង្ហាញក្នុងមេរៀននីមួយៗ អ្នកបង្រៀនគឺធ្វើឡើងក្នុង ទម្រង់ជា វីដេអូ និង PowerPoint សម្រាប់ការមេរៀនទាំងនោះ ។

បន្ថែមលើនេះទៀត អេភីស៊ីអាយស៊ីធី(APCICT) បានធ្វើការវិវឌ្ឍន៍ជាមណ្ឌលសហការតាមប្រព័ន្ធអេឡិចត្រូនិច (e-Collaborative Hub) សម្រាប់ ICTD (e-Co Hub – http://www.Unapcict.org/ecohub), វេបសាយដែលបាន បង្ហាញនេះ សម្រាប់អ្នកហ្វឹកហាត់ និង អ្នកបង្កើតច្បាប់ ICTD ផ្លាស់ប្តូរបទពិសោធន៍នៃការហ្វឹកហ្វឺន និង ការសិក្សា របស់ពួកគេ ។ e-Co Hub មួយនេះ អនុញ្ញាតឲ្យធ្វើការស្វែងយល់ចំពោះប្រភពចំណេះដឹងទៅលើទិដ្ឋភាពផ្សេងៗពីគ្នា នៃ ICTD និងផ្តល់នៅកន្លែងទំនេរសម្រាប់ការអនុវត្តទៅវិញទៅមកក្នុងការចែករំលែកនៅចំណេះដឹង ព្រមទាំង បទពិសោធន៍, និង ជាការសហការដើម្បីពន្លឿនលើវិស័យ អាយស៊ីធីឌី(ICTD)។

# មេរៀនទី ៧

មេរៀននេះផ្តល់នូវសេចក្តីផ្តើមពន្យល់អំពីគោលគំនិតមូលដ្ឋាននៃការគ្រប់គ្រងគម្រោងដែលពាក់ព័ន្ធទៅនិងគម្រោងICTD។ មេរៀននេះចាប់ផ្តើមពន្យល់នូវវិធីសាស្ត្រ ដំណើរការនិងបែបបទនៃការគ្រប់គ្រងដែលប្រើប្រាស់ជាទូទៅដោយអ្នកអនុវត្តការគ្រប់គ្រងការអភិវឌ្ឍនិងការគ្រប់គ្រងសេវាICT។ ករណីសិក្សាខ្លះ ឧបករណ៍អនុវត្តនិងគំរូត្រូវបានផ្តល់ឲ្យ ហើយបញ្ហាប្រឈមមុខជាច្រើនក្នុងការរៀបចំផែនការនិងការគ្រប់គ្រងគម្រោងICT ត្រូវបានគូសបញ្ជាក់ផងដែរ។

## គោលបំណងរបស់មេរៀន

មេរៀននេះមានគោលបំណង

១. ផ្តល់នូវគោលគំនិតជាទូទៅ គោលការណ៍និងដំណើរការនៅក្នុងការរៀបចំផែនការនិងការគ្រប់គ្រងគម្រោងICT ។

២. ពិភាក្សាលើបញ្ហានិងការប្រឈមនានានៅក្នុងការរៀបចំផែនការនិងការគ្រប់គ្រងគម្រោងICT ក្នុងបរិបទប្រទេសកំពុងអភិវឌ្ឍន៍និង

៣. ពិពណ៌នាអំពីវិធីសាស្ត្រនិងឧបករណ៍សម្រាប់គ្រប់គ្រងគម្រោងICT ។

## លទ្ធផលទទួលបានពីការសិក្សា

បន្ទាប់ពីសិក្សាអំពីមេរៀននេះហើយ អ្នកអានអាចៈ

. ពិភាក្សាអំពីគោលគំនិត គោលការណ៍និងដំណើការក្នុងការគ្រប់គ្រងគម្រោងICT

. ពីភាក្សាបញ្ហានិងការប្រឈមនានាក្នុងការរៀបចំផែនការនិងការគ្រប់គ្រងគម្រោងICTក្នុងបរិបទប្រទេសកំពុងអភិវឌ្ឍន៍និងអាចស្នើឡើងនូវដំណោះស្រាយនិងវិធីសាស្ត្រដែលពាក់ព័ន្ធ

. ប្រើនូវឧបករណ៍ច្រើនបែបយ៉ាងក្នុងការគ្រប់គ្រងគម្រោងICTតាមជំហាននីមួយៗនិង

. អាចពិនិត្យវាយតម្លៃយ៉ាងមានហេតុផលលើការគ្រប់គ្រងដែលមានស្រាប់និងលើគម្រោងICTដែលបានស្នើឡើង។

## មាតិកា

បុព្វកថា.......................................................................................................

អារម្ភកថា....................................................................................................

អំពីក្រុមមេរៀន ………………………………………………………………………………
មេរៀនទី៧…………………………………………………………………………………
គោលបំណងនៃមេរៀន…………………………………………………………………
លទ្ធផលទទួលបានពីការសិក្សា…………………………………………………………...
បញ្ជីផ្នែកសិក្សាស្វែងយល់…………………………………………………………...
បញ្ជីនៃប្រអប់នានា………………………………………………………………..
បញ្ជីនៃផម្មានរូបនានា……………………………………………………………… .
បញ្ជីនៃតារាងនានា………………………………………………………………..
អក្សរកាត់…………………………………………………………………………
បញ្ជីនៃសញ្ញាសំគាល់នានា…………………………………………………………
១. គោលគំនិតសំខាន់ៗក្នុងការគ្រប់គ្រងគម្រោងICT ………………………………...…..
១.១. ការគ្រប់គ្រងគម្រោងនិងICT សម្រាប់ការអភិវឌ្ឍ……………...
១.២. តើអ្វីទៅជាការគ្រប់គ្រងគម្រោង ?
១.៣. ជំហានគ្រប់គ្រងគម្រោងICTD
១.៤. វិចទ័រនៃការគ្រប់គ្រងៈមនុស្ស ដំណើរការនិងបច្ចេកវិទ្យា
១.៥. បទពិសោធន៍ពីការងារជាក់ស្តែង
២. ការគ្រប់គ្រងគម្រោងICT ធនធានមនុស្សនិងការចូលរួមពីអ្នកពាក់ព័ន្ធ
២.១. ធនធានមនុស្សហើយនិងការគ្រប់គ្រងការផ្លាស់ប្តូរ
២.២. ការវិភាគពីអ្នកពាក់ព័ន្ធនិងការចូលរួម
២.៣. ម្ចាស់គម្រោង
២.៤. អ្នកផ្គត់ផ្គង់គម្រោងនិងម្ចាស់ជំនួយ
២.៥.អ្នកជះឥទ្ធិពល
២.៦. អ្នកការពារគម្រោង
២.៧. អ្នកគ្រប់គ្រងគម្រោង
២.៨. សមាជិកគម្រោង
៣. និយមន័យនៃការផ្តួចផ្តើមគម្រោង ការរៀបចំផែនការនិងការកំណត់ទំហំនៃគម្រោងៈ គោលការណ៍បញ្ហានិងការអនុវត្ត
៣.១. ការផ្តួចផ្តើមគម្រោងៈ បង្កើតករណីសិក្សាសម្រាប់គម្រោង
៣.២. ការសិក្សាពីភាពដែលអាចទៅរួច

៣.៣. វិធីសាស្ត្របែបឡូស្សីក

៣.៤. លំដាប់នៃផែនការគម្រោង

៣.៥. កំណត់ចង្អុលនិងផលិតផលដែលទទួលបាន

៣.៦. ការរៀបផែនការសម្រាប់សកម្មភាពធំៗនៃគម្រោង

៣.៧. ការិយាល័យគ្រប់គ្រងគម្រោង

៤.ការអនុវត្តគម្រោង ការពិនិត្យតាមដានគម្រោង និងការត្រួតពិនិត្យៈ គោលការណ៍ បញ្ហានិងការអនុវត្ត

៤.១. ដំណើរការអនុវត្តការគ្រប់គ្រងគម្រោងICT

៤.២. ការគ្រប់គ្រងពេលវេលា

៤.៣.ការគ្រប់គ្រងចំណាយ

៤.៤. ការគ្រប់គ្រងគុណភាព

៤.៥. ការគ្រប់គ្រងការផ្លាស់ប្តូរ

៤.៦.ផែនការទំនាក់ទំនងៈយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងការផ្លាស់ប្តូរ

៤.៧.ការគ្រប់គ្រងហានិភ័យ

៤.៨. ការគ្រប់គ្រង

៤.៩.ការគ្រប់គ្រងការទទួលយក

៥. ការត្រួតពិនិត្យគម្រោងៈ គោលការណ៍ បញ្ហានិងការអនុវត្ត

៥.១. ការត្រួតមើលពីភាពរីកចម្រើន

៥.២. ការរាយការពីភាពរីកចម្រើន

៦. ការបិទគម្រោងៈ គោលការណ៍ បញ្ហានិងការអនុវត្ត

៦.១. ការទទួលយកលទ្ធផលគម្រោង

៦.២. ការវាយតម្លៃគម្រោង

៦.៣. ការទទួលយកមេរៀន

៧. សកម្មភាពក្រោយពេលគម្រោងបញ្ចប់ៈ ការដាក់ប្រព័ន្ធICTទៅក្នុងការប្រតិបត្តិនិងបញ្ហានៃនិរន្តរភាព

៧.១. បរិដ្ឋានគោលនយោបាយ

៧.២.សមត្ថភាពសម្រាប់ការថែរទាំនិងការរីកចម្រើន

៧.៣. ការអំពាវនាវបន្ត

ឧបសម្ព័ន្ធ

អានបន្ថែម

សន្ទានុក្រម

កំណត់ចំណាំសម្រាប់គ្រូបង្វឹក
អំពីអ្នកនិពន្ធ

## បញ្ជីផ្នែកសិក្សាស្វែងយល់

១. ប្រព័ន្ធធ្វើការដោយស្វ័យប្រវត្តិ: ការកែលំអឲ្យមានភាពប្រសើរឡើងក្នុងផ្តល់សេវានិងប្រសិទ្ធិភាព
២. គម្រោងបណ្តាញកុំព្យូទ័រក្រុងក្នុងប្រទេសប្រេស៊ីល: The Pirai Digital Project
៣. កម្មវិធីសិក្សាតាមប្រព័ន្ធអេឡិចត្រូនិចនៅប្រទេសឈីលី

## បញ្ជីនៃប្រអប់នានា

ប្រអប់ទី ១: និយមន័យនៃ”គម្រោង”
ប្រអប់ទី ២: និយមន័យនៃ”ការគ្រប់គ្រងគម្រោង”
ប្រអប់ទី ៣: បទពិសោធពីគម្រោងICTD
ប្រអប់ទី ៤: ទម្លាប់ដើម្បីផ្តួចផ្តើមការអភិវឌ្ឍគម្រោងICTឲ្យមានប្រសិទ្ធិភាព

## បញ្ជីនៃរូប

រូប១: កម្មវិធីយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រ
រូប២ វង្វិលខួបនៃគម្រោង
រូប៣ វង្វិលខួបនៃប្រព័ន្ធICT
រូប៤ មនុស្ស ដំណើរការ និងបច្ចេកវិទ្យាដល់ការគ្រប់គ្រងគម្រោង
រូប៥ ដំហាននៃផែនការគម្រោង
រូប៦ គំនូសតាងបញ្ហា
រូប៧ គំនូសតាងនៃការវិភាគបញ្ហា
រូប៨ គំនូសតាងបញ្ហាភ្ជាប់ជាមួយនិងLFA
រូប៩ កម្រិតនៃផែនការគ្រប់គ្រងគម្រោង
រូប១០ ឧទាហរណ៍អំពីរចនាសម្ព័ន្ធនៃការគ្រប់គ្រងគម្រោង
រូប១១ សកម្មភាពគ្រប់គ្រងគម្រោងក្នុងជំហាននៃការអនុវត្តគម្រោងICT
រូប១២ ហានិភ័យ
រូប១៤ ការទាក់ទងខាងការវាយតម្លៃ សកម្មភាពត្រួតពិនិត្យជាមួយនិងLFAនៃគោលដៅ

## បញ្ជីនៃតារាងនានា

តារាង១: ការប្រៀបធៀប គម្រោងធម្មតានិងគម្រោងICT
តារាង២ កំណត់ចង្អុលផ្សេងៗក្នុងជំហាននីមួយៗនៃគម្រោង
តារាង៣ និយមន័យនៃជំហាននៃការគ្រប់គ្រងគម្រោងទៅតាមប្រភេទគម្រោង

តារាង៤ ការរៀបចំដ៏ល្អនិងភាពពិតជាក់ស្តែងនៃការគ្រប់គ្រងគម្រោងICT
តារាង៥ គុណភាពនិងទេពកោសល្យសម្រាប់អ្នកគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាព
តារាង៦ គំរូវិភាគអំពីអ្នកដែលពាក់ព័ន្ធនឹងគម្រោង
តារាង៧ តារាងថវិកាសម្រាប់វាយតម្លៃពីនិរន្តរភាព
តារាង៨ ផលប្រយោជន៍និងលទ្ធផលខ្លះៗដែលកើតឡើងពីគម្រោង
តារាង៩ វិធីសាស្ត្រLFA
តារាង១០ តារាង
តារាង១១ ការពិព័ណ៌នាពីLFAទៅតាមកម្រិត
តារាង១៣ បញ្ជីនៃកំណត់ចង្អុលគម្រោងនិងលទ្ធផល
តារាង១៤ ការរៀបចំផែនការភារកិច្ច សកម្មភាពនិងលទ្ធផល
តារាង១៥ គំរូនៃគំនូសតាងGanttសម្រាប់ជំហានផលិត
តារាង១៦តារាងពេលវេលាសម្រាប់ផែនការការងារ
តារាង១៧គំរូស្តង់ដាគុណភាព
តារាង១៨ ការដឹងពីគុណប្រយោជន៍

បញ្ជីពាក្យកាត់

| | |
|---|---|
| អេឌីប៊ី (ADB): | ធនាគារអភិវឌ្ឍន៍អាស៊ី (Asia Development Bank) |
| អេភីស៊ីអាយស៊ីធី (APCICT): | មជ្ឈមណ្ឌលហ្វឹកហ្វឺនអាស៊ីនិងប៉ាស៊ីហ្វិចនៃវិស័យបច្ចេកវិទ្យាពត៌មាន និង គមនាគមន៍ សម្រាប់ការអភិវឌ្ឍន៍ (Asia and Pacific Training Centre for Information and Communication) |
| អេស៊ីន (ASEAN): | សមាគមជាតិអាស៊ី អគ្នេយ៍ (Association of Southeast Asian Nations) |
| ប៊ីភីអូ (BPO): | បំរើការប្រតិបត្តិនៃជំនួញ (Business Process Outsourcing) |
| ស៊ីឌី (CD): | ស៊ីឌី |
| ស៊ីអឹមអេ (CMA): | សកម្មភាពនៃទំនាក់ទំនង និង ពហុពត៌មាននានា (Communications and Multimedia Art) |
| ឌីអរអេអែម (DRAM): | ថាមពលអង្គចងចាំ (Dynamic Random and Multimedia Art) |
| អ៊ីអែសស៊ីអេភី (ESCAP): | គណកម្មាធិកានៃសង្គមនិងសេដ្ឋកិច្ចសម្រាប់អាស៊ីនិង ប៉ាស៊ីហ្វិច |
| អ៊ុយូ (EU): | សហគមអឺរ៉ុប (European Union) |

**មេរៀនទី៧** ទ្រឹស្តីនិងការអនុវត្តក្នុងការគ្រប់គ្រងគម្រោងICT

អេហ្វអូអេសអេស (FOSS): កម្មវិធីបើកចំហនិងសេរី (Free and Open Source Software)

ជីស៊ីអាយអូ (GCIO): ប្រធានគ្រប់គ្រងមន្ត្រីបច្ចេកវិទ្យា (Government Chief Information Officer)

ជីអាយអេហ្វ (GIF): គម្រោងគ្រប់គ្រងអន្តរប្រតិបត្តិ (Government Interoperability Framework)

ជីអិនភី (GNP): ផលទុនជាតិសរុប (Gross National Product)

ជីអេសឌី (GSD): ការអភិវឌ្ឍន៍កម្មវិធីជាសកល (Global Software Development)

អាយស៊ីធី (ICT): វិស័យបច្ចេកវិទ្យា ពត៌មាន និង គមនាគមន៍ (Information and Communication Technology)

អាយស៊ីធីឌី (ICTD): វិស័យបច្ចេកវិទ្យា ពត៌មាន និង គមនាគមន៍សម្រាប់ការអភិវឌ្ឍន៍ (Information and Communication Technology for Development)

អាយឌីអេ (IDA): អាជ្ញាធរអភិវឌ្ឍន៍វិស័យគមនាគមពត៌មានវិទ្យានៃប្រទេសសិង្ហបុរី (Infocomm Development Authority of Singapore)

អាយអឹមអេហ្វ (IMF): មូលនិធិរូបិយបណ្ណអន្តរជាតិ (International Monetary Fund)

អាយភី (IP): ពិធីការប្រព័ន្ធអ៊ីនធើរណិត (Internet Protocol)

អាយធី (IT): បច្ចេកវិទ្យាពត៌មាន (Information Technology)

អាយធីយូ (ITU): សហគមទូរគមនាគមអន្តរជាតិ (International Telecommunication Union)

អិនអ៊ីអេ (NEA): សហគ្រាសស្ថាបត្យករជាតិ (National Enterprise Architecture)

អិនជីអូ (NGO): អង្គការមិនមែនរដ្ឋាភិបាល (Non-Governmental Organization)

អិនអាយឌីអេ (NIDA): អាជ្ញាធរជាតិទទួលបន្ទុកអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា ពត៌មាន និង គមនាគម ប្រទេសកម្ពុជា (National Information Communication Technology Development Authority, Cambodia)

អិនអាយអាយ (NII): ហេដ្ឋារចនាពត៌មានជាតិ (National Information Infrastructure)

អូអ៊ីស៊ីឌី (OECD): អង្គការសម្រាប់ការអភិវឌ្ឍន៍និងសហប្រតិបត្តិការសេដ្ឋកិច្ច (Organization for Economic Co-operation and Development)

អូអេសអេស (OSS): កម្មវិធីបើកចំហ (Open Source Software)

ភីស៊ី (PC): កុំព្យូទ័រផ្ទាល់ខ្លួន (Personal Computer)

ភីអិលឌីធី (PLDT): ក្រុមហ៊ុនទូរស័ព្ទចម្ងាយឆ្ងាយនៃប្រទេសហ្វីលីពីន (Philippines Long Distance Telephone Company)

ភីដប់ប៊ីយូស៊ី (PWC): PricewaterhouseCoopers

**មេរៀនទី៧** ទ្រឹស្តីនិងការអនុវត្តក្នុងការគ្រប់គ្រងគម្រោងICT

អរ&ឌី (R&D): ស្រាវជ្រាវនិងការអភិវឌ្ឍន៍ (Research and Development)

អរអេអេខេអេស (RAAKS): ការវាយតំលៃរហ័សនៃប្រពន្ធ័ចំណេះដឹងផ្នែកកសិកម្ម (Rapid Appraisal of Agricultural Knowledge Systems)

ធីអេ (TA): ជំនួយការបច្ចេកវិទ្យា (Technical Assistance)

យូខេ (UK): ចក្រភពអង់គ្លេស (United Kingdom)

យូអិន (UN): អង្គការសហប្រជាជាតិ (United Nations)

យូអេស (US): សហរដ្ឋអាមេរិច (United States)

វេត (VAT): ពន្ធលើតម្លៃបន្ថែម (Value Added Tax)

វីស៊ីអរ (VCR): ប្រដាប់ថតការសែតវីដេអូ (Video Cassette Recorder)

ដាប់ប៊ីយូអេសអាយអេស (WSIS): ជំនួបកំពូលពិភពលោកទៅលើសង្គមពត៌មានវិទ្យា (World Summit on the Information Society)

## បញ្ជីនៃសញ្ញាសំគាល់នានា

ករណីសិក្សា

សំនួរត្រិះរិះ

លំហាត់

លំហាត់សាកល្បង

# ១. គោលគំនិតសំខាន់ៗក្នុងការគ្រប់គ្រងគម្រោង បច្ចេកវិទ្យា គមនាគមន៍និងពត៌មាន (ICT)

អត្ថបទផ្នែកនេះមានគោលបំណង:

-បង្ហាញពីភាពទូទៅនៃការគ្រប់គ្រងគម្រោង ICTសម្រាប់ការអភិវឌ្ឍ (ICTD) និង

-កំណត់គោលគំនិតសំខាន់ៗ ក្នុងការគ្រប់គ្រងគម្រោងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន រួមមានចំណេះដឹង ជំហានមូលដ្ឋាននិងដំណើរការមូលដ្ឋានក្នុងការអនុវត្តគម្រោង ហើយនិងធាតុនិងសំខាន់ៗសម្រាប់គ្រប់គ្រងគម្រោង។

ភ្នាក់ងាររដ្ឋាភិបាលភាគច្រើន តែងមានផែនការនិងការអនុវត្តគម្រោងអភិវឌ្ឍន៍នានា។ គម្រោងទាំងនោះទោះជាមានទំហំតូចឬធំសុទ្ធតែជាផ្នែកមួយនៃបរិយាកាសដ៏ធំជាងនោះ។គម្រោងទាំងនោះតែងជាប់ទាក់ទងនៅនឹងកម្មវិធីផ្សេងៗ ទាក់ទងទៅនឹងគោលដៅនិងគោលបំណងរបស់ស្ថាប័នមួយ។ នៅពេលដែលគម្រោងបានបញ្ចប់សព្វគ្រប់ គម្រោងនោះអាចក្លាយជាផ្នែកមួយនៃដំណើរប្រតិបត្តិការក្នុងស្ថាប័ន្ឋនោះ។ នៅក្នុងន័យនេះ គម្រោងនីមួយៗសុទ្ធតែជួយឲ្យគោលដៅបេសកម្មនិងចក្ខុវិស័យរបស់ស្ថាប័នមួយមានភាពល្អប្រសើរឡើង។

យោងទៅលើហេតុផលមួយនេះ  ក្របខ័ណ្ឌការងារសម្រាប់បង្កើតនិងអនុវត្តគម្រោងទាំងឡាយមានភាពចាំបាច់បំផុត។ The Academy of ICT Essentials for Government Leaders series ដែលមានរួមបញ្ចូលទាំងផ្នែកនេះដែរនោះ ទទួលយកនូវការអភិវឌ្ឍប្រកបដោយអត្ថន័យដ៏ធំធេងដូចដែលបានចែងនៅក្នុងគោលដៅអភិវឌ្ឍន៍សហសវត្ស សម្រាប់ជាក្របខ័ណ្ឌក្នុងការរៀបចំផែនការណ៍ អនុវត្តនិងវាយតំលៃគម្រោងជំនួយលើវិស័យ ICT។ វគ្គទី១ ដែលបរិយាយអំពីទំនាក់ទំនងរវាងកម្រងកម្មវិធីICT ជាមួយនិងការអភិវឌ្ឍប្រកបដោយអត្ថន័យពេញលេញ បានលើកឡើងយ៉ាងច្បាស់អំពីក្របខ័ណ្ឌនៃការប្រើប្រាស់វិស័យ ICT  ក្នុងបរិបទប្រទេសកំពុងអភិវឌ្ឍន៍។

វគ្គនេះ ផ្តោតទៅលើការគ្រប់គ្រងគម្រោង ICT។ ការគ្រប់គ្រងគម្រោង ICT គឺជារឿងដ៏លំបាកមួយ។ អ្នកគ្រប់គ្រងគម្រោងចាំបាច់ត្រូវគិតគូរគ្រប់ទិដ្ឋភាពទាំងអស់នៅក្នុង ការរៀបចំផែនការនិងការអនុវត្តគម្រោង រួមមានទាំង ការកំណត់ទិសដៅ ការចាត់ចែង ការគ្រប់គ្រងធនធាននិងការគ្រប់គ្រងការចំណាយ ការប្រគល់លទ្ធផលនៃគម្រោងទៅឲ្យម្ចាស់គម្រោងទាំងឡាយ។ ភារកិច្ចរបស់អ្នកគ្រប់គ្រងគម្រោងកាន់តែមានភាពស្មុគស្មាញឡើងនៅពេលដែលគម្រោង ICT ត្រូវបានអនុវត្តក្នុងជួររដ្ឋាភិបាល។ រដ្ឋាភិបាលមាននូវគោលដៅនៃការអភិវឌ្ឍ រីឯភ្នាក់ងាររដ្ឋាភិបាលមាននូវផែនការរបស់គេដើម្បីបង្ហាញអំពីគោលដៅក្នុងការផ្តល់សេវាកម្មហើយនិងសិទ្ធិអំណាចរបស់ខ្លួន។ ហេតុនេះ គម្រោងICTឬកម្មវិធីICT ទាំងឡាយចាំបាច់ត្រូវតែដើរស្របគ្នាជាមួយនិងទិសដៅនិងសិទ្ធិអំណាចទាំងនេះ។ លើសពីនេះទៅទៀត អ្នកពាក់ព័ន្ធផ្សេងៗទៀតនៅក្នុងគម្រោងICT

និងកម្មវិធីICTទាំងនោះ រួមទាំងសាធារណជនទៀតសោធនោះ តែងតែមាននូវការប្រាថ្នាចង់បានខ្ពស់។

ការប្រឈមទាំងឡាយនៅក្នុងការរៀបចំផែនការនិងគ្រប់គ្រងគម្រោង ICT នឹងត្រូវលើកមកបញ្ជាក់នៅក្នុងវគ្គនេះ។ វិស័យចំណេះដឹងសំខាន់ៗក្នុងការគ្រប់គ្រងគម្រោង ICT  ដំណាក់កាលគ្រប់គ្រងគម្រោងហើយនិងដំណើរការគ្រប់គ្រងគម្រោងទៅតាមដំណាក់កាលផ្សេងៗនោះនឹងត្រូវលើកយកមកពិភាក្សាដែរ។

១.១ ការគ្រប់គ្រងគម្រោងនិង វិស័យ**ICT**សម្រាប់ការអភិវឌ្ឍ

**តើ គម្រោង គឺជាអ្វី?**

ពាក្យថា គម្រោង នេះគឺជាពាក្យសាមញ្ញដែលសឹងតែមិនចាំបាច់ផ្តល់នូវនិយមន័យទៅហើយ។ ប៉ុន្តែមុននឹងពិនិត្យមើលលើនិយមន័យមួយចំនួន ចូរអនុវត្តសកម្មភាពខាងក្រោមសិនៈ

លំហាត់
ដោយពឹងផ្អែកលើបទពិសោធទ័ផ្ទាល់ខ្លួនរបស់លោកអ្នក ចូរសាកល្បងផ្តល់និយមន័យដល់ៈ
១. គម្រោង
២. គម្រោង ICT

នៅក្នុងប្រអប់ខាងក្រោមមានផ្តល់នូវនិយមន័យមួយចំនួនចំពោះពាក្យ គម្រោងៈ

**ប្រអប់១. និយមន័យនៃពាក្យ  គម្រោង**

“គម្រោងគឺជាការទទួលធ្វើទាំងប្រថុយប្រថានក្នុងរយៈពេលបណ្តោះអាសន្នមួយដែលមានការចាប់ផ្តើមនិងការបញ្ចាប់មានកំណត់ ហើយមានគោលបំណងបង្កើតផលិតផលឬសេវាកម្មជាក់លាក់មួយ។

*ប្រភព (Microsoft Solutions Framework white Paper: MSF Project Management Discipline v.1.1(June 2002), 8, http://download.microsoft.com/download/b/4/f/b4fd8a8a-5e67-4419-968e-ec7582723169/MSF%20Project%20Management%20Discipline%20v.%201.1.pdf)*

"គម្រោងគឺជាការប្រឹងប្រែងបណ្តោះអាសន្នមួយដើម្បីបង្កើតផលិតផលឬសេវាកម្មមួយ។ ជាទូទៅគម្រោងតែងតែមាននូវការកម្រិតនិងភាពប្រថុយប្រថានខាងផ្នែកចំណាយ ពេលវេលា និងលទ្ធផល។"
*ប្រភព(James R. Chapman(1997). http://www.hyperthot.com/pm_into.htm)*

"គម្រោងគឺជាបណ្តុំមួយនៃសកម្មភាពសម្របសម្រួលជាច្រើន ដែលមានចំនុចចាប់ផ្តើមនិងចំនុចបញ្ចប់ច្បាស់លាស់ ហើយទទួលបំពេញដោយមនុស្សម្នាក់ឬ មនុស្សមួយក្រុម ដើម្បីសម្រេចបានទៅតាមគោលបំណងជាក់លាក់ ក្នុងរយៈពេលកំណត់មួយ ក្នុងការចំណាយជាក់លាក់ និងមានលទ្ធផលជាក់លាក់ដូចដែលបានកំណត់ក្នុងរឿងជំនួញ។"
*ប្រភព (Office of Government Commerce, "Project Management" http://www.ogc.gov .uk /delivery_lifecycle_project_management.asp)*

"គម្រោងគឺជាសេរីនៃសកម្មភាពដែលមាននូវគោលបំណងសម្រេចគោលដៅជាក់លាក់និងច្បាស់លាស់ក្នុងរយៈពេលកំណត់មួយនិងក្នុងការចំណាយថវិការកំណត់មួយ។"
*ប្រភព(European Commission, Aid Delivery Method: Volume 1- Project Cycle Management Guidelines(Brussels: European Commission, 2004), 8, http://ec.europa.eu/europeaid/multimedia/publications/documents/tools/eupopeaid_adm_pcm_guidelines_2004_en.pdf)*

សរុបសេចក្តីទៅ គម្រោងគឺជាការអនុវត្តការងារបណ្តោះអាសន្នដែលប្រើប្រាស់ធនធាន ត្រូវការការចាយវាយនិងបង្កើតលទ្ធផលតម្រូវតាមការរំពឹងទុក តាមពេលវេលាកំណត់ដើម្បីសម្រេចបានគោលដៅជាក់លាក់ណាមួយ។ គម្រោងមានច្រើនបែបច្រើនយ៉ាង អាចខុសគ្នាទៅតាមទំហំ រយៈពេលអនុវត្តនិងភាពស្មុគស្មាញ។

បើយោងទៅតាម សៀនូ " គម្រោងមានលក្ខណៈស្រដៀងទៅនិងការប្រតិបត្តិនិងកម្មវិធីនានាដែលក្នុងនោះវាអាចបង្កើតអ្វីមួយតាមការរំពឹងទុក តែត្រូវការប្រើប្រាស់ធនធាននិងការចំណាយ។

” ប៉ុន្តែ “ ប្រតិបត្តិការគឺជាសកម្មភាពដែលត្រូវធ្វើជាបន្តរហូតនិងដដែលៗ គម្រោងមិនមានលក្ខណៈដូចនេះទេ។” ឧទាហរណ៍ខ្លះៗនៃសកម្មភាពប្រតិបត្តិមានដូចជា តំហែទាំប្រព័ន្ធផ្ទុកទិន្នន័យរៀងរាល់មួយសប្ដាហ៍ម្ដងនិងសកម្មភាពតំហែទាំប្រព័ន្ធកុំព្យូទ័រឬបណ្ដាញកុំព្យូទ័រជាដើម ។ល។ ចំណែកឯ “ កម្មវិធីវិញមានលក្ខណៈធំជាងគម្រោង និងមានភាពស្មុគស្មាញជាងហើយមានរួមបញ្ចូលសកម្មភាពប្រតិបត្តិដដែលៗដូចជាការងារតំហែទាំនិងការគ្រប់គ្រងស្ថានការណ៍ ។ល។” កម្មវិធីជាធម្មតាត្រូវបានគេផ្ដល់គម្រោងថវិការក្នុងមួយឆ្នាំម្ដង។ គម្រោងជាទូទៅមានរយៈកាលកំណត់ជាងកម្មវិធី។”[1]

គម្រោង ICT បានលេចឡើងនៅក្នុងអំឡុងពេលបីទសវត្សចុងក្រោយនៃសតវត្សទី២០នេះ។ សម្រាប់គោលបំណងដ៏ច្រើនសន្ធឹកសន្ធាប់របស់យើង យើងឲ្យនិយមន័យលើគម្រោង ICT ថាជាដំណោះស្រាយដោយពឹងផ្អែកលើវិស័យ ICTដើម្បីអាចឆ្លើយតបទៅនឹងតម្រូវការសេវាកម្មនិងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល។ គម្រោងទាំងនេះមាននូវដំណើរការនិងវិធីសាស្ត្រដែលផ្គត់ផ្គង់ដោយវិស័យ ICT។ គម្រោងទាំងនេះគឺជាគម្រោងដែលផ្ដើមឲ្យមានការផ្លាស់ប្ដូរក្នុងស្ថាប័នណាមួយដោយប្រើប្រាស់វិស័យបច្ចេកវិទ្យាក្នុងគោលបំណងផ្ដល់នូវផលប្រយោជន៍ចំពោះស្ថាប័ននោះហើយនិងអតិថិជនគោលដៅទាំងឡាយ។

ភាពខុសប្លែកគ្នារវាងគម្រោងធម្មតាឬគម្រោងមិនមែនICT(conventional or non-ICT project) និងគម្រោងICT

តារាង ១ បង្ហាញពីចំនុចនៃភាពខុសគ្នារវាងគម្រោងមិនមែន ICT និងគម្រោង ICT។

តារាង ១. ការប្រៀបធៀបរវាងគម្រោងមិនមែនICT និងគម្រោងICT

| គម្រោងធម្មតា/មិនមែន ICT | គម្រោង ICT |
|---|---|
| - ឆ្ពោះទៅបំពេញតម្រូវការសេវាកម្មនិងយុទ្ធសាស្ត្រគ្រប់គ្រងទាំងឡាយ<br>- មានផ្គត់ផ្គង់ពីម្ចាស់កម្មសិទ្ធិ<br>- មានកាលបរិច្ឆេទចាប់ផ្ដើមនិងបញ្ចប់ | - ឆ្ពោះទៅបំពេញតម្រូវការសេវាកម្មនិងយុទ្ធសាស្ត្រគ្រប់គ្រងទាំងឡាយ<br>- មានផ្គត់ផ្គង់ពីម្ចាស់កម្មសិទ្ធិ<br>- មានកាលបរិច្ឆេទចាប់ផ្ដើមនិងបញ្ចប់ |

[1] ប្រុយណូ សៀណូ ( Bruno Ciano ). Project and Program Management http://brunociano.blogspot.com

| | |
|---|---|
| ច្បាស់លាស់<br>- ព្រំដែននៃគម្រោងត្រូវបានកំណត់និងត្រូវបានកត់ត្រាជាឯកសារ<br>- មានចរិការច្បាស់លាស់<br>- មានលទ្ធផលចុងក្រោយជាក់លាក់ទៅតាមការរំពឹងទុក<br>- ឆ្លើយតបទៅតាមលក្ខខណ្ឌគុណភាព<br>- ប្រើប្រាស់ធនធានដែលកំណត់ឲ្យ | ច្បាស់លាស់<br>- ព្រំដែននៃគម្រោងត្រូវបានកំណត់និងត្រូវបានកត់ត្រាជាឯកសារ<br>- មានចរិការច្បាស់លាស់<br>- មានលទ្ធផលចុងក្រោយជាក់លាក់ទៅតាមការរំពឹងទុក<br>- ឆ្លើយតបទៅតាមលក្ខខណ្ឌគុណភាព<br>- ប្រើប្រាស់ធនធានដែលកំណត់ឲ្យ<br>- ប្រើប្រាស់ដំណោះស្រាយទាំងឡាយដែលមានមូលដ្ឋានលើ ICTដើម្បីបំពេញតម្រូវការសេវាកម្មនិងយុទ្ធសាស្ត្រគ្រប់គ្រងដែលបានកំណត់<br>- ផ្តើមណែនាំដំណើរការនិងវិធីសាស្ត្រដែលផ្គត់ផ្គង់ដោយបច្ចេកវិទ្យាព័ត៌មាន |

*ប្រភព John Macasio, ICT Project Management Practitioner Network 2008,*
http://ictpmpractitioner.ning.com

លំហាត់
តើលោកអ្នកអាចគិតឃើញពីភាពខុសគ្នាផ្សេងទៀតរវាង គម្រោងមិនមែន ICT និង គម្រោង ICT ដែរឬទេ? ចូរបន្ថែមការរកឃើញទៅក្នុងតារាង ១ ខាងលើ។

តើគេបង្កើតគម្រោងឡើងដើម្បីអ្វី?

គម្រោងជាទូទៅគឺជាការឆ្លើយតបទៅនឹងតម្រូវការបន្ទាន់ ឆ្លើយតបទៅនឹងបញ្ហា ឬក៏ករណីជំនួញណាមួយក្នុងស្ថាប័នណាមួយ។ ប៉ុន្តែនៅពេលដែលទិសដៅរបស់គម្រោងមួយគឺដើម្បីឆ្លើយតបទៅនឹងតម្រូវការបន្ទាន់ គម្រោងគួរតែរៀបឡើងសម្រាប់គោលបំណងឬគោលដៅធំៗ។ គម្រោង ICT ជាធម្មតាទទួលធ្វើឡើងដោយអ្នកគ្រប់គ្រងដើម្បីបំពេញចន្លោះខ្វះខាតក្នុងការដំណើរការគ្មាន

ប្រសិទ្ធិភាពនិងមិនមានលទ្ធផលល្អក្នុងដំណើរការគ្រប់គ្រង។ គម្រោង ICT មានគោលបំណង បង្ហាញនិងផ្គត់ផ្គង់គោលដៅអភិវឌ្ឍន៍ខ្នាតធំដូចជា MDGs។

មិនថាគម្រោងICT ខ្នាតប៉ុណ្ណានិងអស់តម្លៃប៉ុណ្ណានោះទេ វាមានសារសំខាន់ណាស់ចំពោះអ្នកគ្រប់គ្រងគម្រោងដើម្បីដឹងនិងយល់ពីហេតុផលសម្រាប់អនុវត្តគម្រោងហើយនិងថាតើវាទាក់ទងនិងគោលដៅធំៗរបស់ស្ថាប័នដោយរបៀបណា។ ខាងក្រោមនេះគឺជាឧទាហរណ៍នៃកម្មវិធី គ្រប់គ្រប់តាមប្រព័ន្ធអេឡិចត្រូនិច ដែលវិវត្តឡើងចេញពីគម្រោងICT ដែលត្រូវបានអនុវត្តឡើងជាផ្នែកនៃផែនការអភិវឌ្ឍជាតិរយៈពេលមធ្យមនិងវែង។

ដំណើរការការងារដោយស្វ័យប្រវត្តិ៖ ជម្រុញប្រសិទ្ធិភាពនិងជម្រុញការផ្តល់សេវាកម្ម

ដំណើរការគ្រប់គ្រងដោយស្វ័យប្រវត្តិអាចជាការងារដ៏ពិបាកមួយសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលប្រទេសជាច្រើននោះទទួលរងគ្រោះដោយសារការិយាយាលធិបតេយ្យដែលគ្មានតម្លាភាព ពុករលួយ និង គ្មានប្រសិទ្ធិភាព។ ក្នុងករណីទាំងនេះ ការបង្កើតនូវប្រព័ន្ធអេឡិចត្រូនិចជួបប្រទះនូវបញ្ហាច្រើនក្រៅតែពីបញ្ហាបច្ចេកវិទ្យាព័ត៌មាននោះទៅទៀត វារួមបញ្ចូលទាំងតម្រូវការវាយតម្លៃពេញលេញនិងការរៀបចំការគ្រប់គ្រងរបស់របស់រដ្ឋាភិបាលឡើងវិញ ការរក្សាទុកឯកសារនិងការគ្រប់គ្រងចំណេះដឹង។ ដំណើរការទាំងនេះគឺជាកត្តាវាយតម្លៃភាពជោគជ័យឬបរាជ័យរបស់គម្រោងរដ្ឋាភិបាលអេឡិចត្រូនិច។ ទោះបីជាមានភាពលំបាកច្រើនក៏ដោយ រដ្ឋាភិបាលកណ្តាលនិងរដ្ឋាភិបាលមូលដ្ឋាន នៅក្នុងប្រទេសមួយចំនួនដូចជាប្រេស៊ីល ឈីលី ឥណ្ឌានិងហ្វីលីពីន បានអនុវត្តនូវប្រព័ន្ធតម្រូវការផ្គត់ផ្គង់តាមអេឡិចត្រូនិច ប្រព័ន្ធគ្រប់គ្រងពន្ធនិងប្រព័ន្ធគ្រប់គ្រងដទៃទៀត។ ការកែទម្រង់ទាំងនេះបានជម្រុញឲ្យមានការទទួលខុសត្រូវតម្លាភាពនិងជំនឿទៅលើសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការផ្តល់សេវាកម្មដល់ប្រជាពលរដ្ឋ។

រដ្ឋាភិបាលមូលដ្ឋាននៅរដ្ឋការណាតាកា ក្នុងប្រទេសឥណ្ឌា បានបង្កើតនូវប្រព័ន្ធចុះបញ្ជីដីធ្លី Bhoomi ដ៏ធំទូលាយនិងគួរឲ្យស្ងើចសរសើរមួយ។ ដោយប្រើប្រាស់នូវបច្ចេកវិទ្យាសម្គាល់តាមជីវិមាត្រសាស្រ្ត ការថតបញ្ចូលឯកសារនិងការដាក់ពង្រាយនូវតូបព័ត៌មានជាច្រើននោះ ប្រព័ន្ធនេះបានកត់ត្រាក្បាលដីប្រមាណ២០លានចាប់តាំងពីឆ្នាំ១៩៩៨។ លើសពីនេះទៅទៀត រដ្ឋប៊ីហាបានអនុវត្តប្រព័ន្ធជំនួយតាមបណ្តាញព័ត៌មានដើម្បីគ្រប់គ្រប់ពន្ធលើការលក់(អាការលើផលរបរ) ដែលធ្វើឲ្យការប្រមូលចំនូលពីពន្ធលើការលក់នេះមានការកើនឡើងនិងជួយការពារការគេចវេស

មិនបង់ពន្ធ។ ការប្រើប្រាស់នូវប្រព័ន្ធនេះបានធ្វើឲ្យចំនូលរបស់រដ្ឋដែលបានពីការបង់ពន្ធកើនឡើងជាលំដាប់ចាប់តាំងពីឆ្នាំ ២០០១មក។

នៅក្នុងប្រទេសហ្វីលីពីន ប្រព័ន្ធតម្រូវការផ្គត់ផ្គង់តាមអេឡិចត្រូនិច បានអនុវត្តឡើងដែលអាចឲ្យគេចុះបញ្ជីអ្នកផ្គត់ផ្គង់និងភ្នាក់ងាររដ្ឋាភិបាល អាចបញ្ជាក់ពីតម្លៃផ្គត់ផ្គង់និងវាយឈ្មោះការផ្គត់ផ្គង់ហើយនិង ការដេញថ្លៃ។ នៅក្នុងគេហទំព័រព័ត៌មានរបស់រាជរដ្ឋាភិបាលក៏មាននូវគេហទំព័រពាណិជ្ជកម្មអេឡិចត្រូនិចរបស់ការិយាល័យគយ ដែលផ្តល់បណ្តាញដឹកជញ្ជូនអេឡិចត្រូនិច ២៤ម៉ោងសម្រាប់ឧស្សាហកម្មដឹកជញ្ជូនរបស់ប្រទេស។ មានគម្រោងមួយដែលបង្កើតឡើងដោយប៉ូលីសជាតិជម្រុញឲ្យមានការប្រើប្រាស់សារអេឡិចត្រូនិច ដើម្បីស្វែងរកជំនួយបន្ទាន់ ដើម្បីតវ៉ានិងត្រួតពិនិត្យអំពើពុករលួយរបស់ប៉ូលីសនិងភ្នាក់ងារសាធារណៈដទៃទៀត។

ក្នុងប្រទេស ឈីលី គេហទំព័រ ឈីលី ខូមប្រា (Chili Compra) ផ្តល់ដល់ភ្នាក់ងារសាធារណៈនូវប្រព័ន្ធមួយដែលអាចស្វែងរកព័ត៌មានស្តីពីទំនិញនិងសេវាកម្ម។ គេហទំព័រនេះមានបញ្ចូលទាំងទំព័រព័ត៌មានដែលបង្ហាញពីតម្រូវការថ្មីៗរបស់រដ្ឋាភិបាល ពីការចុះបញ្ជីតាមប្រព័ន្ធOnline សម្រាប់ក្រុមហ៊ុនដែលមានបំណង ធ្វើជំនួញជាមួយរដ្ឋ ហើយនិងបទបញ្ជានិងការណែនាំថ្មីៗស្តីពីតម្រូវការផ្គត់ផ្គង់។ លើសពីនេះ មាននូវវេទិកាពិភាក្សាតាមប្រព័ន្ធអ៊ីនធឺណេត ដែលអនុញ្ញាតិឲ្យអ្នកផ្គត់ផ្គង់និងភ្នាក់ងាររដ្ឋាភិបាលដឹងព័ត៌មានជាច្រើនទៀតស្តីពី ការអនុវត្តដ៏ល្អប្រសើបំផុត កិច្ចសន្យា និងព័ត៌មានទាក់ទងនិងតម្រូវការផ្គត់ផ្គង់ដទៃទៀត។

*ប្រភព Abridged from John Paul, Robert Katz and sean Gallagher, Lessions from the Field, An Overview of the Current Uses of Information and Technologies for Develpement( World Resources Institute, 2004), 33, http://www.digitaldividend.org/pdf/lessions.pdf.*

គម្រោងទាំងអំបាលម្នានដែលបានរៀបរាប់ខាងលើ បាននាំឲ្យមានការផ្លាស់ប្តូរគួរឲ្យកត់សម្គាល់ក្នុងប្រព័ន្ធគ្រប់គ្រងនិងដំណើរការគ្រប់គ្រងក្នុងប្រទេសដែលបានរៀបរាប់ខាងលើ បានធ្វើឲ្យមានភាពរីកចម្រើនក្នុងការផ្តល់សេវាកម្មទាំងនៅក្នុងនិងទូទាំងភ្នាក់ងាររដ្ឋាភិបាលទាំងមូល ភាពរីកចម្រើនក្នុងការផ្តល់សេវាកម្មចំពោះវិស័យជំនួញ និងការផ្តល់សេវាកម្មចំពោះប្រជាពលរដ្ឋ។

មានការកើនឡើងនូវភាពសុទុដ្ឋិនិយមច្រើនចំពោះជំនឿដែលថា បច្ចេកវិទ្យាជាពិសេសនោះគឺ បច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា អាចជួយសម្រេចគោលដៅអភិវឌ្ឍ និងជម្រុញឲ្យមានការរីកចម្រើនឆាប់រហ័សនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ មានការសិក្សាស្រាវជ្រាវជាច្រើនបានលើកឡើងថា ការវិនិយោគលើសេវាកម្មផលិតកម្ម ICT និងការវិនិយោគលើបរិក្ខា ICT ជួយជម្រុញឲ្យមានការរីកចម្រើនខាងផ្នែកសេដ្ឋកិច្ច។[2]ប៉ុន្តែប្រជាជនក្រីក្រនៅតាមជនបទដែលមានចំនួនច្រើនលើសលប់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍នោះ នៅតែមិនទាន់អាចប្រើប្រាស់បច្ចេកវិទ្យា ICT បាននៅឡើយ។ ពាក្យថា” គម្លាតបច្ចេកវិទ្យា( Digital Divide ) “ ត្រូវបានបង្កើតឡើងដើម្បីពិពណនាអំពីគម្លាតរវាងអ្នកដែលទទួលបានការប្រើប្រាស់សេវាកម្ម ICTហើយទទួលបានផលប្រយោជន៍ពីវិស័យនេះ និងអ្នកដែលមិនទទួលបានការប្រើប្រាស់ ក៏ដូចជាមិនទទួលបានផលប្រយោជន៍បន្តិចណាសោះ។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ “គម្លាតបច្ចេកវិទ្យា “នេះមានគម្លាតធំមែនទែន។

ស្ថាប័នអភិវឌ្ឍសង្គមនានាហើយនិងភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិបានព្យាយាមផ្តួចផ្តើមនិងបង្កើតកម្មវិធីអភិវឌ្ឍក្នុងគោលបំណងផ្តល់ដល់ប្រជាពលរដ្ឋទាំងនោះនូវការប្រើប្រាស់បច្ចេកវិទ្យាICT ដើម្បីទទួលបាននូវផលប្រយោជន៍ពីវិស័យនោះ។ នៅពេលដែលមានការសិក្សាតាមលក្ខណៈវិទ្យាសាស្រ្តតិចតួចប៉ុណ្ណោះដែលអាចអះអាងពីទំនាក់ទំនងផ្ទាល់រវាងការថយចុះនៃភាពក្រីក្រដោយសារតែការប្រើប្រាស់និងការរីកចម្រើននៃវិស័យបច្ចេកវិទ្យា ICT ភស្តុតាងតូចៗនិងឧទាហរណ៍នៃការផ្តួចផ្តើមឲ្យមានការប្រើប្រាស់បច្ចេកវិទ្យា ICTនៅតាមសហគមន៍មូលដ្ឋានបានបង្ហាញអំពីគោលគំនិតនៃចលនាបង្កើនការរប្រើប្រាស់បច្ចេកវិទ្យាICT សម្រាប់ការអភិវឌ្ឍ។ វគ្គទី១នៅក្នុងAPCICTtraining series បានពិភាក្សាអំពីឧទាហរណ៍នៃការផ្តួចផ្តើមតាមសហគមន៍ដែលបង្ហាញថាតើ គម្រោងដែលប្រើប្រាស់វិស័យICT ជាជំនួយនោះអាចផ្លាស់ប្តូរការរស់នៅរបស់ប្រជាជនក្រីក្រឲ្យមានមានជីវភាពល្អប្រសើបានដោយរបៀបណា។

[2] Isabel Neto, Charles Kenny, Subramaniam Janakiram and Charles Watt, “Chapter 1-Look Before You Leap: The Bumpy Road to E-development,”in E-development : From Excitement to Effectiveness, ed. Robert Shaware ( Washington, D.C,: World Bank, 2005), 1-22, http://www-wds.worldbank.org/servlet/WDSContentServer/WDSP/IB/2005/11/08/000090341_20051108163202/Rendered/PDF/ 341470EDevelopment.pdf.

ចាប់តាំងពីពាក់កណ្តាលទសវត្សទី ៩០មក ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជាច្រើន បានគាំទ្រគម្រោងICTD ជាមធ្យោបាយសម្រាប់ធ្វើឲ្យជីវិតរស់នៅរបស់មនុស្សដែលត្រូវគេចាត់ទុកថាមិនសំខាន់ កាន់តែមានភាពប្រសើរឡើង។ គោលបំណងរបស់គម្រោងICTD គឺដើម្បីទូទាត់ឥទ្ធិពលអវិជ្ជមានដែលវិស័យICTអាចមានចំពោះប្រជាជនក្រីក្រ ដូចជាការមិនរាប់បញ្ចូល រួមមានមធ្យោបាយសកម្មនិងការកែប្រែថ្មីដែលពង្រឹងតួនាទីលើវិស័យជាក់លាក់មួយចំណាយនទាំងការចូលទៅនិងការប្រើប្រាស់បច្ចេកវិទ្យាICT។[3]

រូប១បង្ហាញ ១.ទំនាក់ទំនងនៃគោលនយោបាយកាត់បន្ថយភាពក្រីក្រ ២. កម្មវិធីICTD និងយុទ្ធសាស្ត្រ ហើយនិង ៣.ការគ្រប់គ្រងគម្រោងICTបានល្អ ដែលទាំងអស់នេះគឺដើម្បី៤. ធ្វើជីវិតរស់នៅរបស់ប្រជាពលរដ្ឋមានសភាពល្អប្រសើរ។

រូប១ កម្មវិធីយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ គម្រោងICTD និងICT

រដ្ឋាភិបាលនៃប្រទេសកំពុងអភិវឌ្ឍន៍ឥឡូវនេះកំពុងវិនិយោគលើវិស័យICT។ប៉ុន្តែ គម្រោង ICT ទាំងនោះគឺជាការប្រឹងប្រែងប្រកបដោយភាពប្រថុយប្រថាន។ ការសិក្សាស្រាវជ្រាវបង្ហាញថា ក្រុមហ៊ុន រដ្ឋាភិបាលនិងស្ថាប័នសង្គមស៊ីវិលជាច្រើននៅក្នុងប្រទេសមានការអភិវឌ្ឍន៍តិច(LCDs)ជួបប្រទះការលំបាកច្រើននៅក្នុងការប្រើប្រាស់វិស័យICTsឲ្យបានពេញលេញ។ ការសិក្សាស្រាវជ្រាវរបស់ធនាគារពិភពលោកក្នុងឆ្នាំ២០០៥ បានវាយតម្លៃថាការអនុវត្តគម្រោងICTនៅតាមស្ថាប័នសាធារណៈភាគច្រើន ក្នុងប្រទេសមានការអភិវឌ្ឍតិចនោះ មានការបរាជ័យខ្លះនិងបរាជ័យទាំងស្រុង។ ការបរាជ័យទាំងនោះ គឺដោយសារអាងលើហេតុផលថា ការរៀបចំគម្រោងការណ៍មិនបានល្អ ខ្វះខាតហេដ្ឋារចនាសម្ព័ន្ធ មានបញ្ហាច្បាប់និងបញ្ញាត្តិ ស្ថាប័នរដ្ឋាភិបាលនិងស្ថាប័នខ្សោយ។[4]

[3] Swiss Agency for Developent and Cooperation, SDC ICT 4D Strategy( Berne: SDC:2005 ), 5, http://www.deza.admin.ch/ressources/resource_en_161888.pdf

[4] Neto et al

ដូចដែលបានលើកឡើងខាងលើ
គម្រោងទាំងឡាយទោះជាមានទំហំតូចក៏ដោយក៏គួរតែភ្ជាប់ទៅនឹងបរិដ្ឋានការងារដ៏ធំរបស់ស្ថាប័នមួយ ។ គម្រោងទាំងនោះអាចត្រូវបានអនុវត្តដើម្បីបង្កើនចំណេះដឹង ដើម្បីបញ្ជាក់ពីការទទួលយកអ្វីមួយពិតប្រាកដ ឬដើម្បីសាកល្បងគំរូអ្វីមួយ។ គម្រោងទាំងនេះមាន គោលបំណងរួមមួយ គឺដើម្បីជម្រុញឲ្យមានការផ្លាស់ប្តូរក្នុងស្ថាប័ន និងក្នុងបរិដ្ឋានការងារធំមួយ។

ស្ថាប័នដែលមានគោលបំណងផ្តល់សេវាកម្មដែលមានគុណភាពល្អប្រសើរចំពោះអតិថិជនរបស់ ខ្លួនអាចអនុវត្តគម្រោង ICTDទៅតាមការគ្រប់គ្រងរបស់ខ្លួន។ ការជម្រុញ ការគ្រប់គ្រងតាមប្រព័ន្ធ អេឡិចត្រូនិចដើម្បីផ្តល់េសវា អាចប្រើប្រាស់វិស័យ ICT ដើម្បីធ្វើឲ្យការផ្តល់សេវាកម្មទាំងនោះមានភាព រីកចម្រើន។ ការផ្តួចផ្តើមទាំងនេះអស់តំលៃថ្លៃ ពីព្រោះវាត្រូវការប្រើប្រាស់បច្ចេកវិទ្យា និងធនធានដ៏ទៃទៀត។ ហេតុនេះការអនុវត្តគម្រោងល្អគឺជាការចាំបាច់េដើម្បីធានាពីតំលៃនៃការចំណាយទាំងនោះ។ វិធីសាស្ត្រយុទ្ធសាស្ត្រគឺជាវិធីសាស្ត្រតាមដំណាក់កាល ដែលផែនការទាំងឡាយហើយនឹងក្របខ័ណ្ឌការងារទាំងឡាយត្រូវបានបំបែកចេញជាការងារច្រើនយ៉ាង ឬក៏គម្រោងច្រើន។ ការអនុវត្តគម្រោងទាំងនេះត្រូវការជាចាំបាច់នូវផែនការជាក់លាក់ ហើយនិងការអង្កេតអំពីការអនុវត្តល្អៗនៅក្នុងការគ្រប់គ្រង គម្រោង។

ខាងក្រោមនេះគឺជាការរាយនូវការអនុវត្តល្អប្រាំពីរយ៉ាងក្នុងការអនុវត្តគម្រោង៖

១.ការកំណត់អំពីទំហំ និងគោលបំណងនៃគម្រោង-ការដឹងអំពីអ្វីដែលត្រូវធ្វើនិងទទួលបាន

២.កំណត់អំពីអ្វីដែលត្រូវផ្តល់ឲ្យគេ-
ដឹងអំពីផលិតផលដែលចាំបាច់ត្រូវផ្តល់នូវចុងបញ្ចប់នៃគម្រោង និងត្រូវដឹងអំពីការទទួលបាន និងយល់ព្រមពីមនុស្សដែលពាក់ព័ន្ធនៅលើគម្រោងទាំងអស់េនេះ។

៣.កំណត់ផែនការគម្រោង-កំណត់ពីរបៀបដែលលទ្ធផលនៃគម្រោងដែលត្រូវសម្រេចបាន ហើយនឹងគិតអំពីតម្រូវការមានដូចជាៈ មនុស្ស ធនធាន ឧបករណ៍ សកម្មភាព និងថវិកាសម្រាប់បញ្ចប់ គម្រោងប្រកបដោយប្រសិទ្ធភាព។

៤.ទំនាក់ទំនង ហើយនិងផែនការទំនាក់ទំនង-
រៀបចំផែនការដើម្បីទាក់ទងជាមួយនឹងមនុស្សដែលពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព។

៥.ឃ្លាំមើលគម្រោង-ពិនិត្យមើលជាបន្តបន្ទាប់ និងជាញឹកញាប់ពីស្ថានភាពទំហំ ពេលវេលា ហើយនិងការចំណាយ។

៦.គ្រប់គ្រងការផ្លាស់ប្តូរ-ពិចារណាថាគួរតែទទួល បដិសេធ ឬក៏បូកបញ្ចូលការផ្លាស់ប្តូរទាំងឡាយ

៧.គ្រប់គ្រងភាពប្រថុយប្រថាន-កំណត់ហេតុការណ៍ដែលអាចជះឥទ្ធិពលមកលើគម្រោង ហើយ បូកបញ្ចូលទៅក្នុងផែនការសកម្មភាពជាចាំបាច់ដើម្បីចៀសវាង ឬបន្ធូរបន្ថយការប្រថុយប្រថានទាំងនេះ

**១អ្វីជាការគ្រប់គ្រងគម្រោង ២.?**

ការគ្រប់គ្រងគម្រោងគឺជារបៀបគ្រប់គ្រងមួយ ដែលកើតឡើងនៅក្នុងពាក់កណ្តាលសតវត្សទី១៩ នៅពេលដែលក្រុមហ៊ុនជាច្រើនចាប់ផ្តើមប្រើប្រាស់នូវគោលការណ៍វិទ្យាសាស្ត្រដើម្បីអនុវត្តការងារ និងដើម្បីឧស្សាហកម្មទាំងមូល។ នៅក្នុងសតវត្សទី២០ នៅពេលដែលបច្ចេកវិទ្យា និងឧស្សាហកម្មកាន់ តែមានភាពស្មុគស្មាញឡើង ការគ្រប់គ្រង់ចាប់ផ្តើមវិវត្តទៅជាសកម្មភាពដែលខុសប្លែកពីការគ្រប់គ្រងជំនួញជាទូទៅ។

ការគ្រប់គ្រងគម្រោងត្រូវបានគេផ្តល់និយមន័យច្រើនយ៉ាង) សូមមើលប្រអប់ទី២ខាងក្រោម(។

**ប្រអប់២ និយមន័យនៃការគ្រប់គ្រងគម្រោង**

”ការគ្រប់គ្រងគម្រោងគឺជាសំណុំនៃរបៀប ការអនុវត្ត និងវិធីសាស្ត្រដែលប្រើប្រាស់សម្រាប់ដឹកនាំក្រុមគម្រោង ហើយនិងគ្រប់គ្រងលើពេលវេលាគម្រោង ការចំណាយ ហើយនិងហានិភ័យ ដើម្បី លទ្ធផលសម្រាប់អតិថិជន“។

”វិធីសាស្ត្រគ្រប់គ្រងគម្រោងដ៏ល្អប្រសើរ និងដឹកនាំគម្រោងតាមរយៈសកម្មភាពដែលមានការពិនិត្យ ការគ្រប់គ្រងល្អ ដើម្បីទទួលបានលទ្ធផលល្អប្រសើរគួរជាទីពេញចិត្ត“។

”ការគ្រប់គ្រងគម្រោងគឺជាចំណេះដឹង ជាទេពកោសល្យ ជាឧបករណ៍ ឬជាវិធីសាស្ត្រដែលគេប្រើប្រាស់ដើម្បីសម្រេចបានគោលដៅរបស់គម្រោងនៅក្នុងលក្ខខណ្ឌយល់ស្របមួយទៅលើគុណភាព ការចំណាយ ពេលវេលា ហើយនិងលក្ខខណ្ឌដទៃទៀត“។

”ការគ្រប់គ្រងគម្រោងគឺជាសំណុំនៃវិធីសាស្ត្រ និងបច្ចេកទេសដែលបានកំណត់យ៉ាងល្អប្រសើរ ដើម្បីគ្រប់គ្រងក្រុមមនុស្ស ដើម្បីសម្រេចបានការងារច្រើនយ៉ាងនៅក្នុងពេលវេលាកំណត់ និងក្នុងថវិកា កំណត់មួយ“។

”ការគ្រប់គ្រងគម្រោងគឺជាការប្រើប្រាស់ចំណេះដឹង ទេពកោសល្យ ឧបករណ៍ និងវិធីសាស្ត្រ ដើម្បីធ្វើសកម្មភាពសម្រេចបាននូវតម្រូវការ និងការរំពឹងទុករបស់មនុស្សជាប់ពាក់ព័ន្ធទាំងឡាយ“។

និយមន័យនៃការគ្រប់គ្រងគម្រោងទាំងនេះបានបញ្ជាក់ថា:

.ការគ្រប់គ្រងគម្រោងគឺជាវិធីសាស្ត្រ ជារបៀប និងជាដំណើរការ

.វាគឺជាសំណុំនៃឧបករណ៍សម្រាប់ធ្វើផែនការសម្រាប់អនុវត្ត សម្រាប់ថែទាំ សម្រាប់ត្រួតពិនិត្យ និងវាយតំលៃពីភាពរីកចម្រើននៃសកម្មភាពទាំងនោះ។

.ស្របគ្នាជាមួយនឹងគោលដៅ ហើយនិងគោលបំណងធំៗរបស់ស្ថាប័នមួយ វាកំណត់ថាតើអ្វីដែលត្រូវសម្រេចបាន។

.បញ្ហាប្រឈមធំៗនៅក្នុងការគ្រប់គ្រងគម្រោងគឺការគ្រប់គ្រងទំហំរបស់គម្រោង និងធនធានពេលវេលា ការចំណាយ និងមនុស្ស។

ក្នុងរយៈពេលច្រើនឆ្នាំកន្លងមកនេះ មានវិធីសាស្ត្រច្រើនយ៉ាងដើម្បីគ្រប់គ្រងគម្រោងបានលេចឡើង ហើយបានអនុវត្តប្រកបដោយជោគជ័យ និងទទួលបានការផ្តល់នូវស្តង់ដា។ ទាំងនោះមានដូចជា

-សៀវភៅស្តីពីចំណេះដឹងនៃការគ្រប់គ្រងគម្រោងដែលមាន ១៨២ទំព័រ បោះពុម្ពដោយវិទ្យាស្ថានគ្រប់គ្រងគម្រោង (PMI) នៅសហរដ្ឋអាមេរិក។ ស្ថាប័ននេះលើកទឹកចិត្ត និងផ្តល់វិញ្ញាបនបត្រដល់អ្នកគ្រប់គ្រងគម្រោងទាំងឡាយដែលប្រើប្រាស់នូវស្តង់ដារបស់គេ (http://www.pmi.org)

-វិធីសាស្ត្រគ្រប់គ្រងគម្រោងនៅក្នុងគ្រប់គ្រងបរិស្ថានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៨៩ ជាស្តង់ដានៃការគ្រប់គ្រង IT ដោយរដ្ឋាភិបាលអង់គ្លេស។ ចាប់តាំងពីពេលនោះមកវិធីសាស្ត្រនេះត្រូវបានគេជម្រុញឲ្យក្លាយទៅជាវិធីសាស្ត្រសម្រាប់គ្រប់គ្រងគម្រោងគ្រប់ប្រភេទទាំងអស់។ ហើយក៏ជាប់ចំណាត់ថ្នាក់នៅខាងក្រៅទាំងផ្នែក IT និងផ្នែកគ្រប់គ្រងដ៏ទៃទៀត។ ស្ថាប័ននោះត្រូវបានគេផ្តល់វិញ្ញាបនបត្រតាមរយៈការប្រឡងដែលត្រួតពិនិត្យដោយសមាគមសម្រាប់ក្រុមគ្រប់គ្រងគម្រោង។Prince 2: បានចុះបញ្ជីនៅក្នុងការិយាល័យពាណិជ្ជកម្មរដ្ឋាភិបាលរបស់ប្រទេសអង់គ្លេស (OGC) (http://www.ogc.gov.uk/method_prince_2.asp)។

-Microsoft Solution Framework (MSF) ដែលវិវត្តចេញឡើងពីការអភិវឌ្ឍន៍កម្មវិធី។ ក្រុមហ៊ុន Microsoft បានអះអាងថា វិធីសាស្ត្រនេះត្រូវបានប្រើប្រាស់យ៉ាងជោគជ័យនៅក្នុងគម្រោងពង្រីករចនាសម្ព័ន្ធដូចដែលបានរៀបចំឡើងដើម្បីផ្តល់តំលៃនៅក្នុងយុគសម័យអុីនធើណិតបច្ចុប្បន្ន។

-The Rational Unified Process (RUP) ដែលជាការផ្តល់ការប្រមូលផ្តុំនៃការបង្កើតដែលកើតឡើងពី Rational Corporation។ វាគឺជាក្របខ័ណ្ឌការងារសម្រាប់អនុវត្តកម្មវិធីដែលឥឡូវនេះជាផលិតផលរបស់ IBM។ វាឋិតនៅក្នុងក្រុម Unified Modeling Language ដែលទទួលយកយ៉ាងទូលំទូលាយជាឧបករណ៍ដែលសម្រាប់បង្កើត និងអភិវឌ្ឍតូចៗ។

-Project Cycle Management (PCM) ដែលពិពណ៌នាអំពីសកម្មភាពគ្រប់គ្រង ហើយនិងទម្រង់ នៃការសម្រេចចិត្ត។ វិធីសាស្ត្រនេះបានប្រើនៅក្នុង Life Cycle នៃគម្រោងមួយ )រួមបញ្ចូលទាំងភារកិច្ច សំខាន់ៗ តួនាទី និងការទទួលខុសត្រូវ ឯកសារសំខាន់ៗ ហើយនិងជម្រើសនៃការធ្វើការការងារសម្រេច ចិត្ត(។ ស្ថាប័នជាច្រើនមានដូចជាក្រុមផ្តល់ជំនួយទ្វេភាគី និងពហុភាគីប្រើប្រាស់ឧបករណ៍និងដំណើរការ PCMនេះ។

-The Logical Framework Approach (LFA) ជាឧបករណ៍វិភាគ បង្ហាញ និងគ្រប់គ្រង បង្កើតឡើងដោយភ្នាក់ងារសហរដ្ឋអាមេរិក សម្រាប់ការងារអន្តរជាតិ (USAID) ហើយនិងក្រុមផ្តល់ជំនួយដ៏ទៃ ទៀត។ វាបង្កើតនូវមែកធាងនៃមធ្យោបាយដែលគោលបំណង និងគោលដៅត្រូវបានទទួលជាមួយនិង ការចង្អុលបង្ហាញហានិភ័យ ហើ ិយនិងការកំណត់អំពីធនធាន ហើយនិងលទ្ធផល។

វិធីសាស្ត្រទាំងអស់នេះ ដើម្បីគ្រប់គ្រងគម្រោង និងត្រូវពិភាក្សាលម្អិតក្នុងវគ្គទី៣ នៃផ្នែកនេះ។

**១ ជំហ៊ាននៃការគ្រប់គ្រងគម្រោង៣.**ICTD

គម្រោង ICTD ទំនងជាគម្រោងដែលចំណាយច្រើន ហើយមានហានិភ័យខ្ពស់ ហេតុនេះដំណើរ ការអនុវត្ត ផលិតផល) មានដូចជា លទ្ធផល ( និងធនធានដែលត្រូវយកមកវិនិយោគគួរតែគ្រប់គ្រង ប្រកបដោយការទទួលខុសត្រូវ។ ពិសេសជាងនោះគម្រោង ICTD ត្រូវការដំណើរការប្រកបដោយភាព ម៉ឺងមាត់ មានរបៀប និងបត់បែន ត្រូវការសម្រេចចិត្តឆាប់រហ័ស ការសហការណ៍ និងការចង្អុលបង្ហាញ ប្រកបដោយការចូលរួម។

គម្រោង ICTD ជាទូទៅត្រូវបានគេយល់ខុស ថាគ្រាន់តែជាសំណុំនៃសកម្មភាពដែលត្រូវការ ឧបករណ៍កុំព្យូទ័រ ត្រូវការប្រព័ន្ធ Network ត្រូវការកម្មវិធី ហើយនិងកម្រងកម្មវិធី ដែលមានគោលបំណង ចុងក្រោយគឺផ្លាស់ប្តូរបច្ចេកវិទ្យា។ ប៉ុន្តែតាមការពិតមានចំនួនសកម្មភាពមនុស្សច្រើនលើសលប់នៅក្នុង គម្រោងទាំងនេះ ហើយគម្រោងនិមួយៗគួរតែភ្ជាប់ទៅនឹងគោលបំណងធំរបស់ស្ថាប័ន។ នៅក្នុងកម្មវិធី ICTD ដ៏ស្មុគស្មាញ និងធំមួយ ការប្រើប្រាស់កំរងកម្មវិធី ICT គឺគ្រាន់តែជាភារកិច្ចមួយ ឬអនុគម្រោងមួយប៉ុណ្ណោះ) សូមមើលករណីសិក្សាខាងក្រោម(។ គម្រោង ICTD មិនមែនជាសកម្មភាពដាច់តែឯង នោះទេ ប៉ុន្តែជាផ្នែកមួយដែលរួមបញ្ចូលទៅក្នុងផ្នែកដធំមួយទៀត )ដូចជាកម្មវិធីមួយ សមាសភាពមួយ យុទ្ធសាស្ត្រមួយ ឬក៏ផែនការយុទ្ធសាស្ត្រមួយ(។

## គម្រោងបណ្តាញក្រុងក្នុងប្រទេស **Brazil: The Pirai Digital Project**

គម្រោងបណ្តាញក្រុងបានចាប់ផ្តើមពីគោលគំនិតនៃ” ការផ្តល់សេវាកម្មទៅកាន់សេចក្តីត្រូវការតាមមូលដ្ឋានហើយនិងរួមបញ្ចូលវិស័យ IT ជាមួយនិងសកម្មភាពអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមក្នុងរូបភាពមួយធំទូលំទូលាយ“។

Pirai គឺជាទីប្រជុំជនដាច់ស្រយាលមួយនៅក្នុងរដ្ឋ Rio De Janeiro ប្រទេស Brazil។ ទីក្រុងនេះ មានប្រជាជនប្រមាណ 25,000នាក់។ នៅចុងទសវត្សឆ្នាំ១៩៩០ គម្រោង Pirai Digital Project បាន ចាប់ផ្តើមឡើងក្រោមការឧបត្ថម្ភរបស់រដ្ឋាភិបាលសហព័ន្ធ ដើម្បីកែលម្អការិយាល័យពន្ធដារនៅតាម តំបន់នោះឲ្យមានភាពទំនើបឡើង។

គោលដៅនៃគម្រោងគឺដើម្បីផ្លាស់ប្តូរឧបករណ៍ទូរគមនាគមន៍ឲ្យមានភាពប្រសើរឡើង ដែលនៅ ពេលនោះមានទូរស័ព្ទ២ខ្សែ កុំព្យូទ័រចំនួន២ ឲ្យក្លាយទៅជាបណ្តាញអត់ខ្សែដែលអាចភ្ជាប់ទៅនឹងការិយាល័យរដ្ឋាភិបាលផ្សេងទៀត។ ប៉ុន្តែនៅពេលដែលការពង្រីកបណ្តាញក្នុងតំបន់ធំជាងនោះ ហើយ អស់តំលៃតិច គណកម្មាធិការសហគមដែលរួមបញ្ចូលទាំងអាជ្ញាធរក្រុង ហើយអ្នកតំណាងមកពីអង្គការ សហគម និងផ្នែកឯកជនដទៃទៀតត្រូវបានបង្កើតឡើង ដើម្បីរៀបចំផែនការមួយពង្រីកការតភ្ជាប់បណ្តាញអត់ខ្សែ ទៅតំបន់ដទៃទៀតនៅក្នុង Pirai។ នេះគឺជាគម្រោងការធំមួយ និងទូលំទូលាយជាងមុន ដើម្បី ធ្វើឲ្យសេដ្ឋកិច្ចក្នុងតំបន់មានច្រើនបែបច្រើនយ៉ាង និងដើម្បីទាក់ទាញការវិនិយោគថ្មីៗ។ គោលបំណង ខាងក្រោយគឺជាតម្រូវការចាំបាច់ និងការប្រើប្រាស់របស់រដ្ឋ បន្ទាប់មកវិនិយោគិនប្រចាំតំបន់ធំៗបានធ្វើ ឯកជនីយកម្ម ហើយបានបញ្ឈប់អ្នកធ្វើការជាច្រើននាក់។

គម្រោងនេះផ្តោតទៅលើវិស័យ៤សំខាន់ៗ: គម្រោងរដ្ឋាភិបាលអេឡិចត្រូនិច គម្រោងការសិក្សា មានដូចជា) ការសិក្សាពីចម្ងាយដោយភ្ជាប់ជាមួយនិងសកលវិទ្យាល័យសាធារណៈ Public Access Point រួមបញ្ចូលទាំងការហ្វឹកហ្វឺនដែលជាកិច្ចសហប្រតិបត្តការជាមួយអង្គការក្រៅរដ្ឋាភិបាលជាច្រើន ( និងការយល់ព្រមពីសហគ្រាសតូច និងមធ្យម។

គម្រោងនេះចំណាយអស់ប្រមាណ ៣៣៦០០ ដុល្លាសហរដ្ឋអាមេរិក ឬប្រហែលជា ២៨០០ដុល្លាសហរដ្ឋអាមេរិក សម្រាប់ភូមិនិមួយៗ។ សកលវិទ្យាល័យ អង្គការក្រៅរដ្ឋាភិបាល និងក្រុមហ៊ុន ឯកជនបានជួយនៅក្នុងគម្រោងនេះ ជាមួយនិងឧបករណ៍ ការអភិវឌ្ឍកម្មវិធី និងអ្នកជំនាញក្នុងការពង្រីក និងប្រតិបត្តបណ្តាញក្រុងនេះ។ បច្ចុប្បន្នបណ្តាញនេះមានប្រមាណ៥០ចំណុចដែលភ្ជាប់ទៅនឹង ការិយាល័យរដ្ឋាភិបាលទាំងអស់

ហើយនិងទៅសាលារដ្ឋ និងបណ្ណាល័យស្ទើរតែទាំងអស់។ បំណុច ប្រើប្រាស់កំពុងមានចំនួនកើនឡើង ហើយក្រុមហ៊ុនឯកជនមួយដែលមានភាគហ៊ុនច្រើន បានបង្កើត ដើម្បីធ្វើពាណិជ្ជកម្មលើសេវាកម្មទៅដល់គ្រួសារ ហើយនិងអ្នកប្រកបជំនួញដូរ។

ជោគជ័យនៃគម្រោង Pirai ប្រហែលជាដោយសារកត្តាជោគជ័យជាច្រើនដូចខាងក្រោមៈ

-ដោយសារតែការខ្វះនូវប្រាក់ទំនុកបម្រុងពីរដ្ឋ) តាំងតែពីជំនួយតូចៗដើម្បីធ្វើឲ្យការិយាល័យធំមានភាពទំនើប (អ្នកដឹកនាំសហគមត្រូវបានបង្ខំចិត្តស្វែងរកធនធានតាមរយៈការសហប្រតិបត្តការជាមួយអ្នកមកពីផ្នែកផ្សេងៗទៀត ដូចជាមកពីវិស័យឯកជន វិស័យសង្គមស៊ីវិល ហើយការរួមគ្នានេះធ្វើឡើងតាមរយៈការប្រមូលផ្តុំ ការសហប្រតិបត្តការ ចែករំលែកគ្រប់បែបយ៉ាង រួមជាមួយបរិការរបស់ទីក្រុង ផងដែរ។

-ការប្រើប្រាស់នូវបច្ចេកវិទ្យាតំលៃទាបសម្រាប់បញ្ជូន) បណ្តាញខាងក្នុងឥតខ្សែ( និងម៉ាស៊ីនទទួល( ដូចជាកម្មវិធីមិនអស់ថ្លៃនិងបើកចំហ) បានធ្វើឲ្យការចំណាយដំបូងមានតម្លៃទាប ដែលនេះអាចធ្វើឲ្យ Pirai ផ្តល់សេវាកម្មBroadband ទៅទីកន្លែងដែលខ្សែពីមុននិងដែលពួកអ្នកផ្តល់សេវាកម្មមិនអាចវិនិយោគបាន។

- ការដឹកនាំនៅថ្នាក់មូលដ្ឋាន អភិបាលកិច្ចល្អ និងទុនសង្គមរឹងមាំអាចធ្វើឲ្យកើតមាននូវផែនការប្រមូលផ្តុំនិងការគ្រប់គ្រងគម្រោងឡើង ដែលអាចជួយបម្រើសេវាកម្មតាមមូលដ្ឋានដែលគេត្រូវការ។

Source: Adapted From Herman Galperin and Bruce Girard, “Microlelcos in Latin America and the Carribean,” in Digital Poverty: Latin American and Caribbean Perspectives, ed. Hernan Galperin and Judith Mariscal (Warwickshire: Intermediate Technology Publications and Ottawa: International Development Research Centre, 2007) 105-107, http://www.dirsi.net/espanol/files/05-Galperin-Girard_23nov.pdf and http://www.crdi.ca/en/ev-112564-201-1-DO_TOPIC.html

Pirai Digital Project បានបង្ហាញថាសមាសធាតុដ៏សំខាន់បំផុតរបស់គម្រោងមួយ មិនមែនជាការបំពាក់នូវប្រព័ន្ធIT នោះទេ ប៉ុន្តែវាគឺជាពង្រីកទៅការអ្នកប្រើប្រាស់និងភ្ជាប់ទៅនិងប្រព័ន្ធផ្សេងៗទៀត។

ជំហានសំខាន់នៃការគ្រប់គ្រងគម្រោង ICTD មានដូចជា ៖ ការរៀបចំផែនការ ការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃ។ មានពាក្យខ្លះទៀត ត្រូវបានគេប្រើប្រាស់ដើម្បីសំដៅទៅលើជំហានទាំងនេះមានដូចជា៖

-ការរៀបចំកម្មវិធី - ការផ្តួចផ្តើមគម្រោង

-ការរៀបចំផែនការ- រៀបគ្រោង រៀបផែនការ និង ដឹកនាំកម្រោង

-ការអនុវត្ត- ការប្រតិបត្តិ

-ការត្រួតពិនិត្យ-ការពិនិត្យឡើងវិញនៅពាក់កណ្តាលប្រតិបត្តិការ

-ការវាយតម្លៃ - ការពិនិត្យមើលឡើងវិញចុងក្រោយ ឬការពិនិត្យវាយតម្លៃធ្វើឡើងពីអ្នកខាងក្រៅ

-បិទគម្រោង (សំដៅលើការបញ្ចប់គ្រប់គ្រងនៃគម្រោង) -ការប្រគល់ទៅឲ្យផ្នែកប្រតិបត្តិការ។

នៅពេលដែលវិធីសាស្ត្រគ្រប់គ្រងគម្រោងផ្សេងគ្នាអាចប្រើប្រាស់ពាក្យផ្សេងៗគ្នាសម្រាប់ជំហាននីមួយៗ កំណត់ចង្អុលដូចគ្នាត្រូវបានគេកំណត់សម្រាប់ជំហាននីមួយៗ (សូមមើលតារាង២)

តារាង២. កំណត់ចង្អុលរបស់គម្រោងទៅតាមជំហាននីមួយៗ

| # | កំណត់ចង្អុលនៅពេលបញ្ចប់ | Martin Tate/ PMI | Microsoft | Rational/UML | Burman | Prince2 | Other |
|---|---|---|---|---|---|---|---|
| 1 | ចក្ខុវិស័យ និងទំហំដែលបានយល់ស្រប | ការចាប់ផ្តើមគម្រោង | | វិភាគ | រៀបចំផែនការនិងយុទ្ធសាស្ត្រ | ចាប់ផ្តើម គម្រោង | ស្រាវជ្រាវដើមដំបូង |
| ២ | រៀបចំផែនការគម្រោងដែលបានយល់ព្រម | រៀបចំផែនការ | រៀបចំផែនការ | រៀបគ្រោង | រៀប គ្រោង និង | រៀបផែនការ និង | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | រៀបគំរូ | របៀបដឹកនាំគម្រោង | |
| ៣ | បញ្ចប់ | ប្រតិបត្តិ | អភិវឌ្ឍ | បង្កើតនិងសាកល្បង | ការផលិត | ការគ្រប់គ្រងតាមជំហាន | |
| ៤ | បញ្ចេញផលិតផល | បិទ | ដាក់ពង្រាយ | ចាប់ផ្ដើមពង្រាយ | សាកល្បង | ការគ្រប់គ្រងដំណើរការ ផ្ដល់ទំនិញ | |

Source: Wilson Mar, “Project Planning Strategies and Tools,”http://www.wilsonmar.com/1projs.htm#ProjPhases.

កំណត់ចង្អុលគឺជាការគូសបញ្ជាក់និងការសំគាល់នៅពេលដែលផលិតផលនៃគម្រោងមួយអាចត្រូវបានបញ្ចប់ឬត្រូវគេទទួលយកនៅរាល់ជំហាននីមួយៗនៃគម្រោង។ ដូចដែលបានបង្ហាញជូនខាងលើ ការបញ្ចប់ទស្សនវិស័យ ទំហំ គឺជាសញ្ញានៃការចប់ជំហានទី១ ( មានឈ្មោះជាច្រើនបានដាក់ឲ្យជំហានដំបូងនេះដូចជាជំហានចាប់ផ្ដើម ជំហានផ្ដួចផ្ដើម ។ល។) ការបញ្ចប់ការរៀបផែនការគម្រោងបង្ហាញពីការចប់ជំហានរៀបចំផែនការ។ល។ វគ្គទី៣នៃផ្នែកនេះ និងពិភាក្សាលំអិតអំពីកំណត់ចង្អុលរបស់គម្រោងឬផលិតផលរបស់គម្រោង។

ក្នុងកិច្ចពិភាក្សាអំពីការគ្រប់គ្រងគម្រោងICTD ផ្នែកនេះប្រើប្រាស់ពាក្យ គម្រោងសាមញ្ញ និងគម្រោងICTបញ្ចូលគ្នា។ តារាងទី៣ បានរាយនូវពាក្យបច្ចេកទេសទាំងនេះ។ ប្រអប់ទី១ បង្ហាញជំហានគ្រប់គ្រងជាលក្ខណៈទូទៅ ប្រអប់ទី២ ផ្ដល់នូវការពិពណ៌នាអំពីជំហាន

នីមួយៗនៅក្នុងគម្រោងសាមញ្ញ ហើយប្រអប់ទី៣ ពិពណ៌នាអំពីចំហាននីមួយៗក្នុងគម្រោងICT។

**តារាង៣ និយមន័យនៃជំហានទាំងឡាយក្នុងការគ្រប់គ្រងគម្រោងតាមប្រភេទគម្រោង**

| ជំហានក្នុងការគ្រប់គ្រងទូទៅ | ជំហានក្នុងការគ្រប់គ្រងគម្រោងធម្មតា | ជំហានក្នុងការគ្រប់គ្រងគម្រោងICT |
|---|---|---|
| ជំហានរៀបចំផែនការ | ការរៀបចំកម្មវិធីគឺជាដំណើរការដែលកម្មវិធីនៃសកម្មភាពជាច្រើនត្រូវបានកំណត់និងដក់ទៅក្នុងផែនការដែលផ្អែកលើគោលនយោបាយ យុទ្ធសាស្ត្រ និងគោលដៅ ហើយនិងសម្រាប់ការគិតពិចារណាក្នុងដំណើរការអភិវឌ្ឍនិងរៀបចំផែនការនៃគម្រោង | ការរៀបចំផែនការសម្រាប់គម្រោងកំណត់ឡើងនូវគោលបំណងរបស់គម្រោង ទំហំកពាក់ព័ន្ធ ការវិភាគអំពីការចំណាយនិងលប្រយោជន៍ និងបង្កើតនូវរបខ័ណ្ឌធនធាននិងការគ្រប់គ្រងគម្រោង។ រទ្ធផលជាចុងបញ្ចប់នៃវគ្គនេះគឺTORនិងវនការគម្រោង<br><br>ការវិភាគអំពីតម្រូវការបានបង្កើតឡើងនូវអ្វីដែលជាលទ្ធផល។ វាទាមទាឲ្យអ្នកចូលរួមទទួលយកនូវដំណឹង គំនិតបែបវិភាគ ជាងការអនុវត្តដូចនៅក្នុងជំហានក្រោយទៀត។ លទ្ធផលចុងបញ្ចប់នៃវគ្គនេះគឺជារបាយការណ៍ស្តីពីតម្រូវការរបស់ប្រព័ន្ធដែលបានយល់ស្រប។<br><br>ការរៀបប្លង់ប្រព័ន្ធបង្កើតនូវរបៀបដែលផលិតផលត្រូវអនុវត្តតួនាទីកំណត់ក្នុងរបាយការណ៍ស្តីពីតម្រូវការរបស់ប្រព័ន្ធ។ លទ្ធផលចុងក្រោយក្នុងវគ្គនេះគឺការការ |

| | | |
|---|---|---|
| | | រៀបប្លង់ប្រព័ន្ធជាក់លាក់ដែលបានយល់ស្របគ្នា។<br>-Logical Design-<br>-Physical Designគឺជាគំនូសតាងឲ្យ Logical Design នៅក្នុងរូបតាងដែលមានកម្មវិធីជាក់លាក់ មានបណ្តាញនិងកុំព្យូទ័រ |
| ដំហានអនុវត្ត | ជំហានរៀបចំផែនការគឺជាជំហានសំខាន់បំផុតក្នុងការប្រតិបត្តិគម្រោង។ នៅក្នុងជំហាននេះដែលសភាពរបស់គម្រោងត្រូវបានគេវាយតម្លៃ ហេតុផល និងការទទួលខុសត្រូវដែលត្រូវបានកំណត់ ពីសក្តានុពល ពីដែនកំណត់នៃតម្រូវការនិងធនធាន( មានពេលវេលា ការចំណាយនិងមនុស្ស) រួមនិងហានិយភ័យដែលបានកំណត់។ រាល់គ្រប់ចំណេះដឹងទាំងអស់អំពីគម្រោងត្រូវរៀបចំនៅក្នុងជំហាននេះ។<br><br>ជំហានអនុវត្តគឺជាជំហានដែលរាល់ផែនការទាំងអស់ត្រូវចាប់ផ្តើមអនុវត្ត។ គោលដៅនៅក្នុងជំហាននេះគឺគ្រប់ដំណើការប្រតិបត្តិនិងធានាឲ្យបានថាយន្តការគ្រប់គ្រងដំណើរការ។ | ការស្ថាបនាពាក់ព័ន្ធនឹងការវាយតម្លៃហើយនិងទទួលយកនូវកម្មវិធី ដែលមានស្រាប់ ការបង្កើតកម្មវិធីបន្ថែម ការគូសបញ្ជាក់លម្អិតអំពីសកម្មភាពដោយដៃ រួមបញ្ចូលធាតុទាំងអស់ទៅក្នុងប្រព័ន្ធទាំងមូល និងការតេស្តកម្មវិធីតាមដំណាក់កាល។  លទ្ធផលនៃវគ្គនេះគឺជាកម្រងកម្មវិធីដែលបានច្របាច់បញ្ចូលដែលសមស្របទៅតាមស្តង់ដាគុណភាព រួមមានការតេស្តតាមតំណាក់កាលច្រើនដង និងមានការកត់ត្រាត្រឹមត្រូវ។<br><br>ការអនវត្តឬការប្រតិបត្តិសំដៅទៅលើការណែនាំសេវាកម្មឲ្យមានការប្រើប្រាស់ដោយអតិថិជន។ លទ្ធផលនៅក្នុងវគ្គនេះគឺសេវាកម្មប្រតិបត្តិដែលបានទទួល។ |

| | | |
|---|---|---|
| ជំហានត្រួតពិនិត្យ | ការត្រួតពិនិត្យគឺជាដំណើរការត្រួតមើលរាល់ផែនការ( ទាំងការបញ្ចូលនិងលទ្ធផល )ហើយនិងស្ទង់ជាគុណភាពដែលផ្តល់ឲ្យ។ របាយការណ៍ ស្តីពីភាពរីកចម្រើន និងរបាយការណ៍ត្រួតពិនិត្យគឺជាឯកសារសំខាន់ដើម្បីដឹងពីហេតុការណ៍និងគ្រប់គ្រងហានិភ័យ។ | ការពិនិត្យឡើងវិញត្រូវធ្វើឡើងនៅចុងបញ្ចប់នៃជំហានទាំងអស់និងនៅពេលភារកិច្ចសំខាន់ៗទាំងអស់ត្រូវបានបញ្ចប់និងតាមដំណាក់កាលនីមួយៗ។ គោលបំណងនៃការពិនិត្យឡើងវិញគឺ៖<br>- ស្ទង់មើលពីដំណើរការទៅមុខនិងភាពយឺតយ៉ាវទាំងឡាយ<br>- រាប់គិតពី ធនធានបានប្រើប្រាស់<br>- ស្វែងយល់ពីការប្រែប្រួលខាងសំភារៈ ពីការលៃលកខាងធនធាននិងពេលវេលាដែលកន្លងទៅ។<br>- កំណត់សកម្មភាពដែលអាចចាំបាច់សម្រាប់កែប្រែបញ្ហាដើម្បីជួយក្នុងការគិតគូរឡើងវិញចំពោះជំហាននិងកិច្ចការដែលមិនអាចបញ្ចប់បាន។<br>- ជួយរៀបចំផែនការនិងភារកិច្ចសម្រាប់ជំហានបន្ទាប់ទៀត។<br>- នៅក្នុងករណីដែលមានការប្រែប្រួលបែបអវិជ្ជមានណាមួយកើតឡើង ការពិនិត្យមើលឡើងវិញនឹងជួយគ្រប់គ្រងព័ត៌មានពីការសម្រេចចិត្តថាបន្តឬមិនបន្តចំពោះគម្រោងនោះបន្តទៀត។ |
| ការវាយតម្លៃ | ពិនិត្យឡើងវិញនិងវាយតម្លៃពីវិធីសាស្ត្រដើម្បី វាស់វែងពីឥទ្ធិពលនៃគម្រោងនិងថាតើវា | |

| | | |
|---|---|---|
| | អាចជួយផ្តល់ដល់គោលដៅធំដុំណាមួយ( ដូចជាកម្មវិធីរដ្ឋាភិបាលនៅលំដាប់ជាតិនិងតំបន់ )។ ការរកឃើញនិងលទ្ធផលនិងបម្រើជាមូលដ្ឋានសម្រាប់ការរៀបចំផែនការនិងសកម្មភាពកម្មវិធីនានានៅពេលអនាគត។ | |
| ជំហានបិទគម្រោង ឬបិទប្រតិបត្តិការ | ការបិទគម្រោងធ្វើឡើងនៅពេលសកម្មភាពគម្រោងទាំងអស់បានបញ្ចប់ហើយនៅពេលដែលលទ្ធផលរួមមានរបាយការណ៍ និងតម្រូវការហិរញ្ញវត្ថុនិងការចំណាយនានាបានបញ្ចប់និងទទួលយកដោយអ្នកពាក់ព័ន្ធទាំងឡាយ។ Source: European Commission, Aid Delivery Method, Volume 1-Project Cycle Management Guidelines( Brussels: European Commission, 2004 ), http://ec.europa.eu/europeaid/multimedia/publications/documents/tools/europeaid_ | ប្រតិបត្តិការគឺជាការបន្តការប្រើប្រាស់ប្រព័ន្ធនិងរួមបញ្ចូលការធ្វើសេចក្តីរាយការណ៍អំពីហេតុការណ៍និងសំណូមពរដើម្បីដោះស្រាយជាមួយភាពមិនប្រក្រតីកើតឡើង និងការផ្លាស់ប្តូរក្នុងប្រព័ន្ធនិងតម្រូវការរបស់អ្នកប្រើប្រាស់។ Source: Roger Clarke, The conventional System life-cycle( Canberra: Xamax Consultancy Pty, Ltd, 2000, http://www.anu.edu.au/people/Roger.Clarke/sos/slc.html. |

| | | |
|---|---|---|
| | adm_pcm_ guidelines_2004_En.pdf | |

អ្នកដែលអនុវត្តការគ្រប់គ្រងគម្រោងភាគច្រើន រួមបញ្ចូលទាំងក្រុមដែលសហការទ្វេរភាគី ឬពហុភាគីក្តី ប្រើប្រាស់PCM។ សហគមអឺរ៉ុប ប្រើប្រាស់ពាក្យសម្រាប់ពិពណ៌នាអំពីសកម្មភាពគ្រប់គ្រងនិងរបៀបរបបធ្វើការសម្រេចចិត្តក្នុងខួបរង្វិលក្នុងគម្រោងមួយ( រួមមានកិច្ចសំខាន់ៗ តួនាទីនិងការទទួលខុសត្រូវ ឯកសារសំខាន់ៗនិងជម្រើសនៃការសម្រេចចិត្ត)។ PCM ធានាបានថា:

-គម្រោងគឺជាការគាំទ្រគោលដៅនៃគោលនយោបាយនៃប្រទេសនិងនៃដៃគូរអភិវឌ្ឍ

-គម្រោងទាក់ទិនទៅនឹងយុទ្ធសាស្រ្តដែលគេបានយល់ស្របមួយហើយនិងបញ្ហាពិតប្រាកដនៃក្រុមទិសដៅឬអ្នកដែលនឹងទទួលប្រយោជន៍

- គម្រោងគឺជាអ្វីដែលអាចធ្វើបាន មានន័យថារាល់គោលដៅនៃគម្រោងគឺអាចសម្រេចបានយ៉ាងពិតជាក់ស្តែងនៅក្នុងលក្ខខ័ណ្ឌនៃដំណើរការប្រតិបត្តិ និងលទ្ធភាពនៃភ្នាក់ងារប្រតិបត្តិនិង

-ប្រយោជន៍ដែលកើតចេញពីគម្រោងគួរតែមាននិរន្តភាព[5]

ជំហានទាំងឡាយនៃគម្រោងធម្មតាជាញឹកញាប់ត្រូវបានបង្ហាញក្នុងគំនូសបង្ហាញជារាងរង្វង់ដូចខាងក្រោម:

**រូប២. រង្វិលខួបនៃគម្រោង**

Source: Adapted from European Commission, Aid Delivery Method: Volume 1-Project Cycle Management Guidelines( Brussels: European Commission, 2004 ), http://ec.europa.eu/europeaid/multimediea/publications/documnets/tools/europeaid_adm_pcm_guidelines_204_en.pdf )

[5] European Commission, op. cit. 17

រូប

នៅក្នុងគម្រោងដែលប្រើប្រាស់ICT ដើម្បីជាជំនួយ ជំហានវង្វិលខួបក៏ត្រូវបានប្រើប្រាស់ និងរៀបចំផែនការហើយត្រូវបានគេដឹងថាជាដំណើរការដ៏សំខាន់។ មាននូវសកម្មភាពសម្រាប់ពិនិត្យមើលឡើងវិញជាច្រើនលើលទ្ធផល ដំណើរការ និងធនធានប្រើប្រាស់ជាមួយនឹងផែនការ។ ដំណើរការគម្រោងដែលមានលក្ខណៈវង្វិលជុំនេះគឺក្នុងបរិបទដែលថាលទ្ធផលលើកទី១ ក្លាយជាផ្នែកមួយនៃដំណើរការហើយការកែប្រែលើកក្រោយត្រូវបានអនុវត្ត។ ក្នុងកម្រងកម្មវិធីរបស់ប្រព័ន្ធ របៀបរបបនេះត្រូវបានគេហៅថាជា ខួបវង្វិលនៃប្រព័ន្ធ។[6]

នៅក្នុងខួបវង្វិលនៃប្រព័ន្ធ គំនូសព្រាងសម្រាប់ខួបវង្វិលនេះត្រូវបានគេភាគច្រើនក្នុងគម្រោងICT ជាលក្ខណៈ ដំណាក់ទឹកធ្លាក់ ឬជាលក្ខណៈកម្លាំងអេឡិចទ្រិចរបស់ឧស្ម័ន( សូមមើលរូប៣ )

**រូប៣ ខួបបង្វិលនៃប្រព័ន្ធ ICT**

ដាក់រូប

ធាតុសំខាន់ៗនៃវង្វិលខួបនៃប្រព័ន្ធICT មាន ៖

-ជំហាន មានសំនុំនៃកិច្ចការដែលពាក់ព័ន្ធ

-កិច្ចការ សកម្មភាពជាក់លាក់ដែលមានគោលបំណងច្បាស់លាស់

-ចំនុចត្រួតពិនិត្យ អាចហៅបានមួយទៀតថា កំណាត់ចង្អុល ឬលទ្ធផលដែលត្រូវផ្តល់ត្រូវបានកណត់ជាលទ្ធផលត្រូវត្រូវផ្តល់អោយនៅពេលបញ្ចប់នៃជំហានណាមួយ ឬបញ្ចប់នៃសំនុំភារកិច្ចណាមួយ។

[6] Roger Clarke, The convetional System Life-Cycle(Canberra: Xamax Consultancy Pty. Ltd, 2000), http://www.anu.edu.au/people/Roger.Clarke/SOS/SLC.html

វគ្គសំខាន់បំផុតនៅក្នុងខួបរង្វិល គឺវគ្គតំហែទាំ វគ្គនេះគឺសំដៅទៅលើរយៈពេលដែលគំរោងត្រូវបានបិទ ហើយលទ្ធផលចុងក្រោយនៃគំរោងនោះត្រូវបានដាក់បញ្ចូលទៅក្នុងការងារប្រតិបត្តិជាប្រចាំរបស់ស្ថាប័ន។ក្រុមគ្រប់គ្រងគំរោងត្រូវតែមានផែនការលំអិត និងអនុវត្តការរៀបចំជាជាក់លាក់សំរាប់ បញ្ចូល និងធ្វើអោយមាននិរន្តភាព នៃលទ្ធផលនៃគំរោង ដែលលទ្ធផលនោះអាចជា ផលិតផល ឬជាប្រតិបត្តិការ (ដូចជា វិធីសាស្រ្ត ថ្មីក្នុងការធ្វើការងារ)

**លំហាត់**

ខាងក្រោមនេះជាសកម្មភាពគំរោង ២៦ ដែលដាក់ចំរុះគ្នា

ចូរកំណត់ពីជំហានដែលសកម្មភាព ឬកិច្ចការមួយៗ ត្រូវស្ថិតនៅក្នុងជំហាននោះ។

| សកម្មភាព ឬកិច្ចការ | ជំហាន |
|---|---|
| ១. កែប្រែគំរោងទៅតាមកាលៈទេសៈដែលផ្លាស់ប្តូរ<br>២. យល់ព្រម និងចុះហត្ថលេខាលើឯកសារផ្តល់ហិរញ្ញវត្ថុ<br>៣. ពិចារណាពីភាពត្រឹមត្រូវផ្នែកបច្ចេកទេស សេដ្ឋកិច្ច ពាណិជ្ជកិច្ច ហិរញ្ញវត្ថុ ការគ្រប់គ្រង ដែលទាក់ទងទៅនឹងគំរោង<br>៤. កំណត់អ្នកដែលពាក់ព័ន្ធនឹងគំរោង<br>៥. សំរេចចំនាយទៅតាមកិច្ចសន្យា<br>៦. ប្រមូលនូវទិន្នន័យដែលទាក់ទងផ្នែកបច្ចេកទេស សេដ្ឋកិច្ច ពាណិជ្ជកម្ម ហិរញ្ញវត្ថុ ការគ្រប់គ្រង និងការចាត់ចែងដែលទាក់ទងទៅនឹងគំរោង<br>៧. ធ្វើសកម្មភាពសាកល្បង ដើម្បីបង្ហាញពីឧទាហរណ៍នៃគោលគំនិត<br>៨. រៀបរាប់លំអិតពីគោលដៅនៃគំរោង<br>៩. កំណត់នូវមធ្យោបាយផ្សេងទៀត ដើម្បីអាចសំរេចគោលដៅនៃគំរោងបាន<br>១០. កំណត់អាទិភាពនៃគំរោងច្រើន ដែលពាក់ពន្ធ័ទៅនឹងផែនការរបស់ផ្នែកមួយ និងរបស់ជាតិ<br>១១. វាយតំលៃ ពីការអនុវត្តគំរោង<br>១២. ធ្វើការសិក្សា និងរបាយការណ៍បញ្ចប់ | |

| | |
|---|---|
| ១៣. ប្រមូលពត៌មានទាក់ទងនឹងផែនការអភិវឌ្ឍន៍ថ្នាក់ជាតិ<br>១៤. ប្រារព្ធកិច្ចប្រជុំត្រីភាគី<br>១៥. កំណត់គំរោងសំរាប់ការរៀបចំលំអិត<br>១៦. អនុវត្តគំរោង<br>១៧. ត្រួតពិនិត្យពីភាពរីចំរើនរបស់គំរោង<br>១៨. ចរចារពីលក្ខខណ្ឌ័នៃការផ្តល់ហិរញ្ញវត្ថុ<br>១៩. កំណត់អាទិភាពរបស់គំរោងទាំងឡាយទៅតាមសារៈសំខាន់ និងទៅតាមលក្ខណៈដែលអាចបំពេញទៅបាន<br>២០.<br>២១.ធ្វើអោយមានសុវត្ថិភាពខាងហិរញ្ញវត្ថុរបស់គំរោង<br>២២. ជ្រើសរើសទីប្រឹក្សា និងក្រុមហ៊ុនសំរាប់ផ្តល់ការប្រឹក្សា<br>២៣. សិក្សាអំពីកិច្ចការគន្លឹះ និងរៀបចំការងារទៅតាមរចនាសម្ព័ន្ធ<br>២៤. សរសេររបាយការណ៍បញ្ចប់ពីគំរោង<br>២៥. បញ្ជាក់ពីតួនាទីរបស់រាជរដ្ឋាភិបាលស្តីពីបញ្ហាដែលបានលើកឡើង ទាក់ទងទៅនឹងគំរោង<br>២៦. បង្ហាញជាសង្ខេបពីគំរោង ហើយនិងកិច្ចយល់ព្រមលើគំរោង | |

## ១.៤ វិចទ័រនៃការគ្រប់គ្រង: មនុស្ស ដំណើរការ និងបច្ចេកវិទ្យា

វិចទ័រនៃការគ្រប់គ្រង គឺជាធាតុផ្សំ ឬ អញ្ញត្តិដែលមានឥទ្ធិពលទៅលើគុណភាព និងល្បឿននៃគំរោងមួយ។ វិចទ័រដែលជាកំលាំងដ៏សំខាន់នៃគំរោងទាំងនោះ គឺជា មនុស្ស ដំណើរការ និងបច្ចកវិទ្យា។ របស់ទាំងអស់នេះកំណត់ពីប្រសិទ្ធភាពគំរោង និងភាពរីកចំរើនឆ្ពោះទៅរកការទទួលបានគោលដៅ និងគោលបំនងនៃគំរោង។

**មនុស្ស**

គំរោងទាំងឡាយត្រូវបានបង្កើត គ្រប់គ្រង និងអនុវត្តឡើងដោយសារមនុស្ស។ អ្នកគ្រប់គ្រងគម្រោង គ្រប់គ្រងដំណើរការនិងបច្ចេកវិទ្យាដើម្បីធានាថាផលិតផលត្រូវបានផ្តល់ ហើយគោលបំណងត្រូវបានឆ្លើយតប។ នៅក្នុងគម្រោងខ្លះទោត ប្រហែលជាគ្មាននរណាម្នាក់ដែលត្រូវគេតែងតាំងជាអ្នកគ្រប់គ្រងគម្រោង។ ប៉ុន្តែមិនថាមានងារបែបណានោះទេ

អ្វីដែលសំខាន់នោះគឺមានមនុស្សម្នាក់ដែលទទួលខុសត្រូវសម្រាប់ដំណើរការបញ្ចប់គម្រោងនោះ។

ក្រៅតែពីអ្នកគ្រប់គ្រងគម្រោង គម្រោងមួយជាទូទៅពាក់ព័ន្ធនឹងអ្នកជំនាញច្រើនធ្វើការជាមួយគ្នាជាក្រុម។ អ្នកគ្រប់គ្រងគំរោងចាំបាច់ត្រូវយល់ដឹងពីតួនាទីរបស់សមាជិកក្រុម ហើយនិងតួនាទីរបស់អ្នកពាក់ពន្ធ័ និងអ្នកដែលទទួលផល។ អ្នកគ្រប់គ្រងគំរោងត្រូវគ្រប់គ្រងការរំពឹងទុករបស់មនុស្សនៅក្នុងគំរោង។ វគ្គទី ២ នៃផ្នែកនេះនឹងរួមបញ្ចូលការពិភាក្សាលំអិតអំពីគំរោង ពីធនធានមនុស្ស និងអ្នកដែលពាក់ពន្ធ័ដទៃទៀត។

**ដំណើរការ**

ដំណើរការដែលប្រព្រឹត្តទៅល្អ ពឹងផ្អែកទៅលើការរៀបចំបែបបទល្អចាប់តាំងពីការគ្រប់គ្រង រហូតដល់ដំណើរការដែលធ្វើឡើងដោយអ្នកប្រតិបត្តិការ និងបុគ្គលិក។ ដំណើរការដែលបានរៀបចំល្អ ហើយនិងជាក់លាក់អាចនាំទៅដល់សក្តានុពលភាព និងជំរុញលទ្ធភាព ឬភាពប្រកួតប្រជែងនៃបុគ្គលិកគំរោង ជាលទ្ធផលនាំអោយមាននូវបុគ្គលិក ដែលមានកំលាំងជំរុញខ្លួនឯងដែលនេះគឺជាចំនុចសំខាន់ឆ្ពោះទៅរកជោគជ័យនៃការគ្រប់គ្រងខាងក្នុង។

នៅក្នុងគំរោងICTភាគច្រើន ជាតុសំខាន់មួយនៃការងារ គឺដំណើរការធ្វើឡើងវិញ ដែលមានន័យថាសកម្មភាព និងឯកសារត្រូវបានពិនិត្យឡើងវិញ ដើម្បីលុបបំបាត់ភាពជាន់គ្នា ឬដំណើរការមិនចាំបាច់នានា។ ប្រសិនបើការពិនិត្យឡើងនេះ មិនត្រូវបានធ្វើទេ ដំណើរការចាស់នឹងបង្កើតលទ្ធផលគ្មានប្រសិទ្ធភាពដូចមុន។

**បច្ចេកវិទ្យា**

បច្ចេកវិទ្យា សំដៅទៅលើម៉ាស៊ីននិងកម្មវិធីក្នុងទីផ្សារដែលត្រូវបានប្រើដើម្បីទ្រទ្រង់គំរូការនិងដំណើរការនៃស្ថាប័នមួយ។ បច្ចេកវិទ្យា មិនគួរយកជាចំនុចដឹកនាំពីគំរូការស្ថាប័ន ឬគំរូការគំរោងនោះឡើយ។ នៅក្នុងគំរោងសហាគមន៏ដែលប្រើប្រាស់បច្ចេកវិទ្យា ICTបច្ចេកវិទ្យាគួរតែស្ថិតនៅខាងក្រោយ ទាល់តែមានគំរូការរបស់មនុស្ស

ឬដំណើរការណាមួយត្រូវបានកំណត់ឡើង។
គំរោងដែលដាក់បច្ចេកវិទ្យានៅមុនសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់
និងសេចក្តីត្រូវការរបស់ដំណើរការ ជាញឹកញាប់ច្រើនតែបរាជ័យ
ហើយធ្វើអោយខាតធនធាន ទាំងពេលវេលា និងការចំណាយផ្សេងៗ។

នៅពេលដែលបច្ចេកវិទ្យាត្រូវបានគេជ្រើសរើសបានល្អ ប្រើប្រាស់បានត្រឹមត្រូវ
និងស្ថាបនាលើគ្រឹះរឹងមាំ បច្ចេកវិទ្យាអាចធ្វើអោយគំរោង
ដំណើរការប្រកបដោយប្រសិទ្ធភាព និងពន្លឿនលំហូរការងាររបស់គំរោង។
ការពិតជាក់ស្តែង សូម្បីតែរបៀបរបបដ៏ប្រសើរបំផុត និងទឹកចិត្តដ៏មុតស្រួចក៏មិនអាច
ជំនួស បច្ចេកវិទ្យាដែលជ្រើសរើសមកប្រើប្រាស់មិនត្រឹមត្រូវ និងមិនមានស្ថេរភាព។
និយាយដោយខ្លី បច្ចេកវិទ្យាអាចជាបញ្ហា ឬជាប្រយោជន៍សំរាប់គំរោងមួយ។

អ្នកគ្រប់គ្រងគំរោង និង ក្រុមអ្នកគ្រប់គ្រងគំរោងត្រូវតែកត់ចំណាំពីសារៈសំខាន់នៃមនុស្ស
ដំណើរការ និងបច្ចេកវិទ្យា ក្នុងការចាប់ផ្តើមធ្វើគំរោងមួយ។ ជាការកំណត់
ការធ្វើអោយមានតុល្យភាព
និងការផ្តុំបញ្ចូលទំនាក់ទំនងនៃធាតុទាំងនេះអាចផ្តល់លទ្ធផលដ៏ប្រសើរបំផុតនៃគំរោង
នោះ។ ( សូមមើលរូបទី ៤ )

ដាក់រូប

**១.៥ បទពិសោធន៍ពីការអនុវត្តជាក់ស្តែង**

គំរោងICTD គឺជាការប៉ុនប៉ងថ្មីមួយ។
ទោះជាយ៉ាងណាក៏ដោយមាននូវបទពិសោធន៍ពីការអនុវត្តជាក់ស្តែងជាច្រើនរួចមកហើយ
ដែលអាចប្រមូលយកមកពិនិត្យមើលបាន។ ភ្នាក់ងារស្ទើសសំរាប់កាតអភិវឌ្ឍន៍
និងសហប្រតិបត្តិការបានរាយវិស័យជាច្រើនដែលពាក់ពន្ធ័ទៅនឹងតំរូវការ
នៅពេលដែលគំរោងICTDត្រូវបំពេញ។( សូមមើលប្រអប់ ៣ )

**ប្រអប់ ៣ បទពិសោធន៍ពីគំរោងICTD**

**ការចូលរួម ៖** មនុស្សដែលជាផ្នែកមួយនៃគំរោងគួរតែចូលរួមតាំងពីតំបូងទី។ តាំងពីការសិក្សាវាយតំលៃតំបូងរហូតដល់លើការត្រួតពិនិត្យចុងក្រោយ។ ការចូលរួមហើយនិងការទាមទារ វាផ្តល់ឥទ្ធិពលដល់សកម្មភាពទាំងឡាយនៃគំរោង ICTD។

**កម្មសិទ្ធិតំបន់ និងការអភិវឌ្ឍន៍សមត្ថភាព ៖** ដើម្បីអោយគំរោងមាននិរន្តភាព គំរោងទាំងនោះត្រូវតែជាកម្មសិទ្ធរបស់តំបន់នីមួយៗ និងមានការអភិវឌ្ឍន៍សមត្ថភាពទាំងខាង ធនធានមនុស្ស ទាំងខាងស្ថាប័ន។ ការប្រើប្រាស់ជាលក្ខណៈរូបវន្ត គឺគ្រាន់តែជាធាតុមួយនៃការប្រើប្រាស់បច្ចេកវិទ្យាICTអោយមានប្រសិទ្ធភាពតែប៉ុណ្ណោះ។ កម្មសិទ្ធិតំបន់ និងការអភិវឌ្ឍន៍សមត្ថភាពនឹងធានាថាបុគ្គលនីមួយៗ សហគមន៍នីមួយៗ និងស្ថាប័នទាំងឡាយអាចប្រើប្រាស់ និងរក្សាប្រពន្ធ័ICT និងអាចទទួលបានផលចំនេញពេញលេញពីការប្រើប្រាស់ទាំងនោះ។

**ការប្រើប្រាស់បច្ចេកវិទ្យាលាយបញ្ចូលគ្នា ៖** ជំរើសបច្ចកវិទ្យា ពឹងផ្អែកជាសំខាន់ទៅលើបរិបទនៃការប្រើប្រាស់ ទំនាក់ទំនងនៃអ្នកប្រើប្រាស់ជាមួយនឹងប្រភេទនៃ ការបញ្ជូនពត៌មាន ជាក់លាក់ត្រូវការការស្រាវជ្រាវបន្ថែម ឥទ្ធិពលនៃវិស័យICTដែលបានកំណត់ដោយ ជំរើសបច្ចកវិទ្យា ដ៏ត្រឹមត្រូវ។

**ការសហការណ៍ជាមួយអ្នកពាក់ព័ន្ធច្រើន៖** ការប្រើប្រាស់បច្ចេកវិទ្យាICT  មានប្រសិទ្ធិភាពមិនត្រឹមតែវិស័យឯកជននិងកម្មវិធីប៉ុណ្ណោះទេ តែអាចជួយជម្រុញឲ្យមានភាពរីកចម្រើននៅតាមសហគមនិងអាចជួយលៃលកធនធានបាន។ ការសហការណ៍ជាមួយអ្នកពាក់ព័ន្ធច្រើនគឺជាចំលើយដ៏សមស្របសម្រាប់ភាពស្មុគស្មាញនៃកិច្ចការនេះដែលអាចឆ្លើយតបទៅនិងការកើនឡើងនៃតម្រូវការធនធាននិងភាពពិតជាក់ស្តែងដែលថាការអភិវឌ្ឍគឺជាការទទួលខុសត្រូវរបស់ផ្នែកទាំងឡាយនៃសង្គម ជាមួយនិងការទំនាក់ទំនងគ្រប់កម្រិត។

**ភាពស៊ីសង្វាក់គ្នា៖** ផលប្រយោជន៍ប្រកបដោយសក្តានុពលសម្រាប់ប្រជាជនក្រីក្រ អាចសម្រេចបាននៅពេលសកម្មភាពរបស់គម្រោង ICTD មានភាពស៊ីសង្វាក់គ្នានិងការខិតខំ

អភិវឌ្ឍន៍ទំហំធំៗរបស់ដៃគូរអភិវឌ្ឍន៍ទាំងឡាយ ជាពិសេសជាមួយការអភិវឌ្ឍដើម្បីកាត់បន្ថយភាពក្រីក្រ។

**ភាពជាម្ចាស់កម្មសិទ្ធនិងភាពជាអ្នកដឹកនាំនៃស្ថាប័ន៖** អារម្មណ៍ជាម្ចាស់កម្មសិទ្ធ និងជាអ្នកដឹកនាំទៅលើស្ថាប័នដៃគូរគឺមានសារសំខាន់ណាស់។ ទោះជាកម្មវិធីសាកល្បងICT បានជោគជ័យដោយសារតែការជម្រុញពីបុគ្គលម្នាក់ៗក៏ដោយ ក៏ត្រូវមានកម្មវិធីទាំងនោះត្រូវមានមូលដ្ឋានលើស្ថាប័នណាមួយដើម្បីពង្រីកគម្រោងនិងបង្កើនចំនួនមនុស្សដែលពាក់ព័ន្ធលើគម្រោងនោះបន្ថែមទៀត។

**បរិដ្ឋានការងារដែលអាចប្រកួតប្រជែង៖** បរិដ្ឋានគោលនយោបាយICTដែលអាចប្រើប្រាស់បាន រួមមានការគោរពទៅលើសេរីភាពនៃការបញ្ចេញមតិ មានព័ត៌មានច្រើនប្រភេទនិងលំហូដោយសេរី ការផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធICTចប់សព្វគ្រប់ និងការវិនិយោគលើសេវាកម្មអភិឌ្ឍន៍រួមបញ្ចូលទាំងមាតិកាប្រចាំតំបន់និងការទទួលយកនូវដំណោះស្រាយប្រភពកូដចំហ។

**ស្ថេរភាពហិរញ្ញវត្ថុនិងសង្គម៖** ដើម្បីឲ្យគម្រោងមួយអាចមានស្ថេរភាពហិរញ្ញវត្ថុបាន រាល់ការចំណាយនិងការបង្កើតចំណូលគួរតែបញ្ចូលក្នុងដំណើរការរៀបចំផែនការចាប់តាំងពីដើមដំបូងមក។ បញ្ហាស្ថេរភាពសង្គម[7]មានសារសំខាន់ស្មើគ្នាហើយនឹងអាចមានស្ថេរភាពបានតាមរយៈ កម្មសិទ្ធិតំបន់និងការបណ្តុះបណ្តាលធនធានមនុស្ស។ វាមានសារសំខាន់ណាស់ក្នុងពិចារណាអំពីស្ថេរភាពសង្គមនិងហិរញ្ញវត្ថុ។

---

[7] ស្ថេរភាពសង្គមសំដៅលើការថែរទាំទុនសង្គម ដែលរួមមានការវិនិយោគនិងសេវាកម្មដែលបង្កើតក្រមខ័ណ្ឌមូលដ្ឋានមួយសម្រាប់សង្គម។ វាធ្វើឲ្យការចំណាយអស់កាន់តែតិចដោយសារការធ្វើការជាមួយគ្នានិងការសហប្រតិបត្តិការ ៖ ការជឿជាក់លើគ្នាធ្វើឲ្យការចំណាយអស់តិចជាង។ មានតែការចូលរួមក្នុងសហាគមប្រកបដោយប្រព័ន្ធត្រឹមត្រូវ និង មានតែសង្គមស៊ីវិលដែលរឹងមាំ រួមជាមួយនិងរដ្ឋាភិបាល ប៉ុណ្ណោះ ដែលអាចធ្វើឲ្យគោលដៅនេះសម្រេចបាន។ ការរួបរួមគ្នាស្អិតរមួតរបស់សហាគមដើម្បីផលប្រយោជន៍រួម ភាពភ្ជាប់ទំនាក់ទំនងគ្នារវាងក្រុមមនុស្សទាំងឡាយ ការចែករំលែក ការអត់អោន ការអាណិតស្រលាញ់ ការអត់ធ្មត់ ការអត់ទ្រាំ មិត្តភាព សេចក្តីស្រលាញ់បានចាត់ទុកថាជាស្តង់ដានៃភាពស្មោះត្រង់ វិន័យ និងសីលធម៌។ ក្រិត្យក្រម ច្បាប់ និងពត៌មាន ដែលបានចែករំលែកបានជម្រុញឲ្យរីកចម្រើនខាងស្ថេរភាពសង្គមនេះ។ ( Robert Goodland, “Sustainability: Human, Social, Economic and Environmental, Encyclopedia of Global Environmental Change( John Wiley&Sons, Ltd.2002 ), http://www.wiley.co.uk/egec/pdf/GA811W.PDF )

**ការគិតគូរអំពីហានិភ័យ៖** ឥទ្ធិពលជាអវិជ្ជមានដែលអាចកើតមានឡើងនិងមិនអាចដឹងមុនបាននោះ ចាំបាច់ត្រូវតែគិតគូរនិងត្រួតពិនិត្យឲ្យបានម៉ត់ចត់ មានរួមថាតើផលប្រយោជន៍នៃការប្រើប្រាស់ICTនោះបានចែកចាយស្មើគ្នាដែរឬទេ ឬក៏ថាតើការប្រើប្រាស់ICT នេះមានលទ្ធផលផ្ទុយពីការប្រាថ្នាចង់បានដែរឬទេ? តើ កាន់តែធ្វើឲ្យសេដ្ឋកិច្ចមិនល្អ កាន់តែធ្វើឲ្យមានគម្លាតសង្គមនិងវប្បធម៌ជាជាងការជួយកាត់បន្ថយភាពក្រីក្រឬយ៉ាងណា?

*ប្រភព:* Adapted from Swiss Agency for Development and Cooperation, SDC ICT 4D Strategy (Berne:SDC, 2005),7. http://www.deza.admin.ch/resources/resurce_en_161888.pdf.

**សំនួរត្រិះរិះពិចារណា**

តើជំហានណាមួយក្នុងការគ្រប់គ្រងគម្រោងដែលអ្នកគិតថា បទពិសោធន៍ក្នុងប្រអប់៣ខាងលើថិននៅក្នុង?

រឿងរ៉ាវទាំងឡាយដែលបានរៀបរាប់នៅក្នុងប្រអប់៣ខាងលើ ភាគច្រើនទាក់ទងទៅនឹងរឿងរ៉ាវសង្គម ជាពិសេសគឺមនុស្ស(អ្នកពាក់ព័ន្ធជាមួយគម្រោង) ដែលជាអ្នកទទួលប្រយោជន៍ចុងក្រោយពីគម្រោង។ បញ្ហាទាក់ទងទៅនឹងការចំណាយ ហានិភ័យ និងបច្ចេកវិទ្យាសមរម្យក៏បានលើកឡើងផងដែរ។ បញ្ហាទាំងអស់នេះត្រូវតែគិតគូរឲ្យបានដិតដល់នៅពេលរៀបចំផែនការនិងអនុវត្តគម្រោង។

ការពិចារណាដ៏សំខាន់មួយក្នុងការគិតគូរពិចារណាសំខាន់ៗដទៃទៀត នៅពេលរៀបចំនិងអនុវត្តគម្រោងICT គឺជាការតម្រូវគ្នារវាងការរៀបចំផែនការគម្រោងនិងបរិបទគម្រោង។ ជាញឹកញាប់ វាតែងតែមានគម្លាតដ៏ធំមួយរវាងការរៀបចំផែនការនិងការពិតជាក់ស្តែង។ វាមានសារសំខាន់ណាស់ក្នុងការទទួលស្គាល់បញ្ហានេះ និងរៀបចំផែនការឲ្យបានសមស្រប។ តារាងទី៤ ខាងក្រោម បានបង្ហាញអំពីការប្រៀបធៀប រវាង គោលគំនិតនៃការរៀបចំផែនការហើយការពិតជាក់ស្តែងក្នុងការគ្រប់គ្រងគម្រោងICT ដែលបានមកពីឯកសាររបស់ ESCAP នៃកម្រងកម្មវិធីICT សម្រាប់ការអភិវឌ្ឍ។

តារាងទី៤ គំនិតរៀបចំផែនការនិងភាពជាក់ស្តែងក្នុងការគ្រប់គ្រងគម្រោងICT

| លក្ខណៈ | គំនិតរៀបចំផែនការ | ភាពពិតជាក់ស្តែង |
|---|---|---|
| ការគ្រប់គ្រងគម្រោងICT | -អ្នកចូលរួមទាំងអស់ នឹងទទួលាបានភាពស្មើគ្នានិងទទួលបានផលស្មើគ្នានៅពេលគម្រោងបានទទួលជោគជ័យ<br>-អ្នកចូលរួមទាំងអស់យល់ពីដំណើរការគ្រប់គ្រងគម្រោងនិងពីតួនាទីនិងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ<br>-ធនធានហិរញ្ញវត្ថុត្រូវបានវិនិយោគទៅតាមកន្លែងដែលត្រូវការបំផុត<br>-ព័ត៌មានអំពី ស្ថានភាពគម្រោងត្រូវចែករំលែកឲ្យបានញឹកញាប់<br>-អ្នកចូលរួមចូលរូមក្នុងការស្វែងរកបញ្ហារួមនិងដោះស្រាយបញ្ហា<br>-ជារួម ក្រុមគម្រោង មានជំនាញដែលចាំបាច់សម្រាប់អនុវត្តគម្រោងប្រកបដោយភាពជោគជ័យ។ | -បុគ្គលម្នាក់ៗនិងស្ថាប័នទាមទារឲ្យមានការផ្លាស់ប្តូរ<br>-គោលដៅរបស់គម្រោងជាញឹកញាប់ទូលំទូលាយ ប៉ុន្តែ ថវិការដើម្បីប្រតិបត្តិតែងតែត្រូវគេប៉ាន់ប្រមាណស្ទើរ<br>-គម្រោងថ្មីៗជាច្រើនចាប់ផ្តើមដោយមានព័ត៌មានតិចតួច មានការដឹកនាំទន់ខ្សោយ  មានការចូលរួមមិនគ្រប់គ្រាន់ មានថវិការតិច និងមានការហ្វឹកហ្វឺននិងទិសដៅមិនលំអិត។<br>-គម្រោងភាគច្រើនត្រូវចំណាយពេលអនុវត្តច្រើនជាងពេលដែលបានគ្រោងទុក<br>-ជាពិសេសនៅក្នុងគម្រោងរបស់រដ្ឋាភិបាល តួនាទីរបស់ភាគីសហប្រតិបត្តិការ ក្នុងការរៀបចំផែនការនិងការគ្រប់គ្រង អាចប៉ះទង្គិចជាមួយនឹងតួនាទីត្រួតពិនិត្យនិងតួនាទី |

| | | |
|---|---|---|
| | | ជានិយ័តករហើយក្លាយទៅជាប្រភពនៃការលំបាកក្នុងទំនាក់ទំនងការងារទាំងឡាយ ។ |

**សំនួរត្រិះរិះពិចារណា**

១. នៅក្នុងបទពិសោធន៍ផ្ទាល់ខ្លួនក្នុងការរៀបចំគម្រោងនិងរៀបផែនការគម្រោង តើភាពពិតជាក់ស្តែងណាមួយដែលបានរៀបរាប់ខាងលើគឺជាបញ្ហាចំបងបំផុត ?មូលហេតុអ្វី ?
២. តើអ្នកគិតថាភាពជាក់ស្តែងនេះកើតឡើងយ៉ាងដូចម្តេច ?

គន្លាតរវាងការរៀបចំគម្រោងនិងបរិបទគម្រោងមិនត្រូវមានគម្លាតខ្លាំងពេកដូចដែលបានរៀបរាប់នៅក្នុងតារាងទី៤នោះទេ។ Bridges.org បានដាក់បញ្ចូលគ្នានូវ “ទំលាប់១២យ៉ាងសម្រាប់ផ្តួចផ្តើម ការអភិវឌ្ឍវិស័យICT ឲ្យមានប្រសិទ្ធិភាពខ្ពស់ “ ដែលអាចអាចផ្តល់លទ្ធផលពិតជាក់ស្តែងល្អប្រសើរសមស្របដូចដែលបានគ្រោងទុក។ ទំលាប់ទាំង១២យ៉ាងនេះអាចត្រូវបានគេប្រើសម្រាប់រៀបចំផែនការឬសម្រាប់ការវាយតម្លៃ។

**ប្រអប់៤. ទំលាប់មួយចំនួនដើម្បីផ្តួចផ្តើមការអភិវឌ្ឍវិស័យICTប្រកបដោយប្រសិទ្ធិភាព**

**ទំលាប់ទី១.** ចាប់ផ្តើមដោយធ្វើកិច្ចការខ្លះៗ។ ពិនិត្យមើលលើអ្វីដែលមានដំណើរការនិងអ្វីដែលមិនដំណើរការ សិក្សាពីការអនុវត្តល្អនៅក្នុងផ្នែកនោះ និងបង្កើនការយល់ដឹងរបស់អស់លោកអ្នក។
**ទំលាប់ទី២.** សិក្សាវាយតម្លៃខ្លះអំពីសហគមន៍ដែលត្រូវផ្តល់សេវាកម្ម។ ការធ្វើដូច្នេះលោកអ្នកអាចធ្វើផែនការអំពីសកម្មភាពចាំបាច់និងជាក់ស្តែងដែលត្រូវធ្វើ។
**ទំលាប់ទី៣.** ធ្វើអ្វីៗទាំងអស់ជាលក្ខណៈមូលដ្ឋាន ធានាឲ្យបាននូវភាពជាម្ចាស់កម្មសិទ្ធិនៅតាមមូលដ្ឋាន ដេញថ្លៃជាលក្ខណៈមូលដ្ឋាន ធ្វើការជាមួយអ្នកមូលដ្ឋាន និងក្នុងបរិបទជាក់លាក់មួយ។

**ទំលាប់ទី៤.** ចូលរួមទទួលខុសត្រូវក្នុងកម្រិតមួយជាមួយអ្នកដោះស្រាយបញ្ហាប្រចាំតំបន់ និងជម្រុញឲ្យពួកគេចូលរួម ទើបពួកគេអាចកំនត់និងដឹងពីបញ្ហាដែលកើតឡើង។
**ទំលាប់ទី៥.** បង្កើតកិច្ចសហប្រតិបត្តិការជាមួយដៃគូរដែលទំនង ហើយធ្វើជាដៃគូសហប្រតិបត្តិការដ៏ល្អជាមួយពួកគេ។
**ទំលាប់ទី៦.** កំណត់គោលដៅច្បាស់លាស់ និងបោះជំហានតូចៗ យឺតដែលអាចសម្រេចបាន។ ត្រូវយល់ដឹងច្បាស់លាស់អំពី លទ្ធផលនិងពេលវេលាកំណត់។
**ទំលាប់ទី៧.** បង្កើតការផ្តួចផ្តើមដែលមានមូលដ្ឋាននៅលើ គោលគំនិតមិនលំអៀងក្នុងការប្រើប្រាស់បច្ចេកវិទ្យា ធ្វើដូចច្នេះ វាអាចមានភាពងាយស្រួលក្នុងការសម្របទៅនិងបច្ចេកវិទ្យាផ្សេងៗនៅពេលដែលពេលវេលាមានការផ្លាស់ប្តូរ។
**ទំលាប់ទី៨.** ជម្រុញឲ្យមានការចូលរួមពីសំណាក់មនុស្សដែលត្រូវគេរើសអើង ពីអាយុ ភេទ ជាតិសាសន៍ឬសាសនា។
**ទំលាប់ទី៩.** កំណត់និងយល់អំពីបញ្ហាប្រឈមខាងក្រៅផ្សេងៗដែលលោកអ្នកនឹងជួបប្រទះ និងបោះជំហានដើម្បីដោះស្រាយបញ្ហាទាំងនោះ។
**ទំលាប់ទី១០.** ត្រួតពិនិត្យនិងវាយតម្លៃការប្រឹងប្រែងរបស់លោកអ្នកដោយប្រើប្រាស់ឧបករណ៍ដែលមានប្រសិទ្ធភាព រាយការណ៍ទៅឲ្យអតិថិជននិងអ្នកគាំទ្រ និងត្រូវសម្របវិធីសាស្រ្តអនុវត្តបើចាំបាច់។
**ទំលាប់ទី១១.** ធ្វើឲ្យការផ្តួចផ្តើមរបស់ខ្លួន មាននិរន្តរភាពរយៈពេលវែងមិនថាជាការនាំយកនូវចំណូលគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ស្ថាប័ន ឬក៏ដោយការផ្តល់នូវបេសកម្មសង្គមដ៏មានប្រសិទ្ធិភាពដែលមានតម្លៃគ្រប់គ្រាន់ក្នុងការទទួលយកជំនួយផ្គត់ផ្គង់របស់ម្ចាស់ជំនួយបន្តទៀត។
**ទំលាប់ទី១២.** ផ្សព្វផ្សាយពត៌មាន អំពីអ្វីដែលលោកអ្នកកំពុងធ្វើនិងអ្វីដែលលោកអ្នកបានរៀនឲ្យបានទូលំទូលាយ ។ ការធ្វើដូច្នេះគឺដើម្បីអាចឲ្យអ្នកដទៃចៀសវាងកំហុសដូចដែលបានកើតឡើងចំពោះលោកអ្នកនិង អាចមានភាពរីកចម្រើនឡើងបន្ថែមទៀតពីការប្រឹងប្រែងរបស់លោកអ្នក។

Source: Abridged from Bridges.org, "12 Habits of Highly Effective ICT-Enabled Development Initiatives". http://www.bridges.org/12_habits.

**លំហាត់សាកល្បង**

១. ហេតុអ្វីបានជាគម្រោងគួរតែភ្ជាប់ទៅនឹងគោលបំណងធំមួយនៅក្នុងសង្គម?

២. តើអ្វីគឺជាធាតុរួមឬលក្ខណៈរួមដែលអាចទាញចេញពីនិយមន័យទាំងឡាយរបស់ការគ្រប់គ្រងគម្រោង?

៣. ហេតុអ្វីបានជាការអនុវត្តការគ្រប់គ្រងគម្រោងដ៏ល្អត្រូវតែប្រើប្រាស់គម្រោងICTD?

៤. អ្វីទៅដែលជាការអនុវត្តល្អៗនិងស្តង់ដារយោង នៅក្នុងការគ្រប់គ្រងគម្រោង?

៥. តើអ្វីគឺជាជំហាននៃការគ្រប់គ្រងគម្រោង? តើអ្វីទៅជាកំណត់ចង្អុលសម្រាប់ជំហាននីមួយៗ?

៦. តើខ្លះជាបទពិសោធន៍ក្នុងបំពេញឬអនុវត្តគម្រោងICTD?

២.ការគ្រប់គ្រងគម្រោងICT ធនធានមនុស្សនិងការចូលរួមរបស់អ្នកដែលពាក់ព័ន្ធ

២.១ ការគ្រប់គ្រងធនធានមនុស្សនិងការផ្លាស់ប្តូរការគ្រប់គ្រង

**មេរៀនទី៧** ទ្រឹស្តីនិងការអនុវត្តក្នុងការគ្រប់គ្រងគម្រោងICT

គ្រប់គំរោងអាចឈានដល់មានលទ្ធផលផ្លែផ្កាគឺតាមរយៈសកម្មមនុស្សផ្តើមពីការចាប់ផ្តើមដល់ការបញ្ចប់គម្រោង។

អ្នកគ្រប់គ្រងលទ្ធផលរបស់គម្រោងគឺជាក្រុមមនុស្សដែលធ្វើការនិងរួមទាំងអ្នកចូលរួមក្នុងគម្រោង។

ជាដំបូង វាជាការសំខាន់ដែលសមាជិកគំរោងគឺត្រូវបានជ្រើសរើសដោយផ្អែកលើលក្ខខណ្ឌច្បាស់លាស់ រួម ទាំង លិខិត យោង ឬក៏ព័ត៌មានការងារដែលបង្ហាញពីតួនាទី មុខតំណែង ល្បឿននៃការងារដែលបានរំពឹងទុក។

ទី២

គេគួរតែចងចាំថាគម្រោងទាំងឡាយអាចធ្វើឲ្យមានការផ្លាស់ប្តូរដែលឆ្លើយតបទៅនឹងសកម្មភាព ប្រតិកម្ម និងការបម្រែបម្រួលអាកប្បកិរិយាក្នុងចំណោមមនុស្សដែលមានការពាក់ពន្ធ័ ។ ការផ្លាស់ប្តូរសំដៅទៅការផ្លាស់ប្តូរតិចតួច ការកែតំរូវ ការប្តូរទ្រង់ទ្រាយដែលបណ្តាលឲ្យមានផលិតផលថ្មីមួយទៀត ដែលមានតម្លៃកាត់ថ្លៃបានឬមិនអាចកាត់ថ្លៃបាន ។ទស្សនៈតែមួយគត់ ,សម្បីតែដំណាក់កាលចាប់ផ្តើមអាចធ្វើឲ្យមានប្រតិកម្មខ្លាំងពីអ្នកទាំងនោះ ។ នៅពេលដែលគំនិតទាំងឡាយសុទ្ធតែថ្មី ហើយមិនច្បាស់ អ្នកទាំងនោះទំនងជាមានចង្ងល់ និងប្រឆាំងនឹងគំនិតថ្មីទាំងនោះ ។ វាពិតណាស់នៅពេលដែលគំនិតទាំងនោះទំនងជាប្រកួតប្រជែងនិងស្ថានភាពបច្ចុប្បន្ន ។

ឧទាហរណ៍ៈគំនិតដែលបង្កើតការិយាល័យសេវាកម្មស្វយត័ក្នុងស្ថាបន័រដ្ឋាភិបាលមួយអាចធ្វើឲ្យមានការប្រឆាំងខ្លាំងក្នុងចំណោមមនុស្សដែលមានការពាក់ពន្ធ័ ។ ប្រតិកម្មសាមញ្ញមួយគឺការភ័យខ្លាចបាត់បង់ការងារ ដែលធ្វើឲ្យមនុស្សម្នាក់មានប្រុងប្រយ្ឌត័ ។មធ្យោបាយមួយដើម្បីកាត់បន្ថម ឬ ធ្វើឲ្យការប្រឆាំងអប្បរិមា គឺការបង្កើតគម្រោងគ្រប់គ្រងការផ្លាស់ប្តូររចនាសម្ពន្ធ័ ជាផ្នែកនៃការងារគ្រប់គ្រងនិងចែកចាយគម្រោង ។ នាយកគ្រប់គ្រងគំរោងក៏អាចធ្វើការ {ស្ទាបស្ទង់មជ្ឈមដ្ឋានជុំវិញ ឬក៏ការប្រមូលគំនិត} ក្នុងជំរើសរបស់សមាជិកក្រុមគំរោង ដែលនឹងបំរើការងារជាភ្នាក់ងារការគ្រប់គ្រងគំរោង។ ផែនការការគ្រប់គ្រងផ្លាស់ប្តូររចនាសម្ពន្ធ័មួយសំដែងនូវការជះឥទ្ធិពល( ភាពវិជ្ជមាននិងភាពអវិជ្ជមាន )នៃការផ្លាស់ប្តូរទៅលើអង្គភាព។សកម្មភាពទាំងឡាយដែលត្រូវបានរួមបញ្ចូលក្នុងផែនការ

នឹងអាស្រ័យលើអត្ថប្រយោជន៍នៃការផ្លស់ប្តូរ និងលក្ខណៈសម្បត្តិរបស់អង្គភាពនោះ ។ប្រសិនបើកត្តាជៈឥទ្ធិពលនៃគម្រោងនោះខ្ពស់ គម្រោងអភិវឌ្ឍន៍រចនាសម្ព័ន្ធកម្រិតខ្ពស់ដាច់ដោយឡែកមួយអាចនឹងត្រូវបានពិចារណា ។ ការទំនាក់ទំនងដើរតួនាទីយ៉ាងសំខាន់មួយក្នុងការគ្រប់គ្រងផ្លាស់ប្តូរ ។បុគ្គលដែលត្រូវបានជួល ឬជាប់កិច្ចសន្យានៃគម្រោង ចាប់ផ្តើមពីអ្នកគ្រប់គ្រងគម្រោងដល់បុគ្គលិកធម្មតាត្រូវតែបញ្ជាក់ឲ្យច្បាស់ពីគោលបំណងរបស់គម្រោង ផែន ការ និងសកម្មភាពទាំងឡាយណាដើម្បីជៀសវាងការចាប់ផ្តើមខុស ។

**2.2 សមាជិកគម្រោង និងដំណើរការគម្រោង**

ការសិក្សាជាច្រើនខាងការអភិវឌ្ឍន៍ ទាមទារឲ្យមានការចូលរួមរបស់សមាជិកដែលអាចមានកត្តាជៈឥទ្ធិពលជាវិជ្ជមានលើគម្រោង និងដំណើរការផែនការ  លទ្ធផល និងនិរន្តរ៍ភាព ។ ពិតណាស់ កម្មវិធីអភិវឌ្ឍន៍ និងគម្រោងជាច្រើនបរាជ័យដោយសារខ្វៈការចូលរួមក្នុងការរចនានិងអនុវត្ត ។ ការចូលរួមត្រូវបានចាត់ទុកជាចេតនាមួយនិងបញ្ចប់មួយយ៉ាងទូលំទូលាយ ។ " ចេតនាមួយ " ការចូលរួមគឺជាដំណើរការមួយក្នុងអ្វីបុគ្គលពាក់ពន្ធ័មានការសហការនិងសំរបសំរួលក្នុងគម្រោងអភិវឌ្ឍននិងកម្មវិធី ។ជាចុងបញ្ចប់ ការចូលរួមគឺជាដំណើរការមួយក្នុងអ្វីបុគ្គលពាក់ពន្ធ័មានការសហការនិងសំរបសំរួលក្នុងគម្រោងអភិវឌ្ឍននិងកម្មវិធី ។ជាចុងបញ្ចប់ ការចូលរួមបានត្រូវមើលឃើញថាជាការពង្រឹងសមត្ថភាពបុគ្គលម្នាក់ៗ និងក្រុមក្នុងចេតនាស្វែងរកជំនាញ ចំណេះដឹង និងបទពិសោធន៍ ដើម្បីឈានទៅធ្វើមានភាពប្រាកដប្រជាលើខ្លួនឯង ។

**ការវាយតម្លៃលើការចូលរួមមាន ៣ចំនុចគួរពិចារណា ៖**

១.គុណភាព និងពង្រីកការចូលរួមសមាជិក

២.តំលៃ និងអត្ថប្រយោជន៍សំរាប់សមាជិកចូលរួម

៣.ផលប៉ះពាល់ លទ្ធផល ល្បឿន និងនិរន្តរ៍ភាព

ចូរពិចារណាករណី Enlance eEducation Program នៅប្រទេស ឆីលី ( Chile ) គម្រោងICT មួយដែលធ្វើឡើងសំរាប់ប្រជាជនក្រីក្រតាមជនបទ ។ មេរៀនមួយដែលបានយកមកសិក្សាក្នុងករណីនេះ គឺថាម្ចាស់គម្រោងគួរតែយកបច្ចេកវិទ្យាជាអតិភាពដើម្បីឲ្យគម្រោងទទួលបានជោគជ័យ ។

ពាក់ព័ន្ធ ទៅនឹងកម្មវិធីអប់រំនៅ chile

ឆ្នាំ ១៩៩១ ,ប្រទេស chile ផ្តើមដំបូងលើកម្មវិធីអប់រំផ្នែក អគ្គីសនី (e-education)ប្លែងពីការបដិសេធន៍នៃការអប់រំ នៅក្នុងជនបទ និង តំបន់ដែលខូចខាត ដោយភ្ជាប់ពីបឋម និង អនុវិទ្យាល័យ ទៅកាន់ internet ការចាប់ផ្តើមកម្មវិធីគឺដឹកនាំនៅក្នុង៦សាលា ក្នុង Santiago និង មានមាត្រាជាបន្តបន្ទាប់ទៀតក្នុងការសំរេចការដឹកនាំកំរិតជាតិ ,កម្មវិធីគ្របដណ្តប់ជាង៩៣%នៃការឧបត្ថមទុនប្រជាជនចំពោះសាលា។៨០%នៃថ្នាក់បង្រៀន ,៨៥០០សាលា ,ជាក់ស្តែងសាលារៀននៅទីក្រុង និងការបណ្តុះសមាមាត្រទៅនិងសាលាជនបទ

អ្នកជំនាញពីធនាគាពិភពលោក ,UNESCO and USAID សន្មត់ថាកម្មវិធីបានសំរេច ,ក្នុងចំណោមផ្សេងទៀត ,សមាជិកអ្នកចូលរួមមានភាពជាក់ស្តែង ដោយ :

-ការផ្តោតទៅលើយុត្តសាស្ត្ររួមបញ្ចូល មិនមែនតែរចនាសម្ព័ន្ធប៉ុន្តែនៅលើការបង្ហាត់បង្រៀន និង

-គោលនយោបាយដែលមានឥទ្ធិពល និងជំរុញការអប់រំទូទាំងប្រទេស ជាមួយនិងត្រួតត្រាកម្មវិធីដោយក្រសួងអប់រំ  និងសម្របសម្រួលជាមួយសមាជិក សំរាប់កិច្ចសន្យា ,ការណែនាំ ,មូលនិធិ និងជំនាញបច្ចេកទេស មកពី៣៥សកលវិទ្យាល័យ

សំរាប់ព័ត៍មានបន្ថែម ចូល http://leanrlink.aed.org.publications/sourcebook/chapter4/chile_casestudy.pdf

## សមាជិកចូលរួម និងភាពជាដៃគូរគម្រោង

ICTD និងគម្រោងរដ្ឋាភិបាលអេឡិចត្រូនិចមានគោលបំណងធ្វើឲ្យសេវាកម្មទាំងឡាយដែលឈានដល់ការផ្លាស់ប្តូរជាវិជ្ជមានកាន់តែប្រសើរឡើងក្នុងជីវភាពប្រជាជន ។ វាមានសារសំខាន់ចងចាំថាគោងដៅចុងក្រោយនៅពេលធ្វើផែនការនិងអភិវឌ្ឍនយុទ្ធសាស្ត្រគម្រោង ។ជាក់ស្តែងណាស់ ចេតនានេះបានឈានមុខការសំរេចចិត្តគម្រោងផ្សេងៗទៀត កត្តាមនុស្សនៃគម្រោង និងការធ្វើឲ្យដំណើរការការចូលរួមនិងការសំរបសំរួលកាន់តែល្អប្រសើរ ។ នេះក្នុងន័យឆ្លើយតបទៅនឹងគម្រោង ICTD ត្រូវតែក្នុងដំណើរកសាងទំនាក់ទំនងខ្នាតធំ និងយូរអង្វែង ។ ការកសាងទំនាក់ទនងគឺជាវិនិយោគមួយដែលគ្រប់គ្រងគម្រោង និងក្រុមគម្រោងត្រូវមានឆន្ទះ និងសមត្ថភាព។

សមាជិកភាពគម្រោងគឺលើសពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀង ដូចជាអនុសាណៈនៃកិច្ចសហប្រតិបត្តិការ ។ ទីភ្នាក់ងារអភិវឌ្ឍនអន្តរជាតិកាណាដា (CIDA) បានកំណត់ពាក្យ សមាជិកភាព "ជាទំនាក់ទនងមួយរវាង មួយនិងច្រើន"សមាសភាពលក្ខន្តិកៈខាងក្រោមបានចែករំលែកទស្សនៈនិងគោលដៅ

ធនធននានា និងព័តមាន ។គណនេយ្យភាពទៅមក និងការសំរេចចិត្តរួមគ្នា
បានលប់ចោលនិយមន័យតួនាទី និងទំនួលខុសត្រូវរបស់ដៃគូនិមួយៗ
ការគោរពទៅមកនិងការទំនាក់ទំនងល្អ
ការផ្លាស់ប្តូរសិក្សាពីររបៀបពីចំណេះដឹងគ្នាទៅវិញទៅមក និងបទពិសោធន៍ការអភិវឌ្ឍន៍
និងភាពប្រហាក់ប្រហែល និងការផ្ទុះផ្គងសមរម្យការពិនិត្យពិច័យ និងបទពិសោធន៍ការអភិវឌ្ឍន៍
។
មានភាពជាដៃគូរក្នុងគម្រោងICTD
ពេលទស្សនៈនិងដំណើរការគម្រោងបានត្រូវកំណត់ដោយសមាជិកទាំងឡាយនៅដំណាក់កាល
ចាប់ផ្តើមគម្រោង ។ ដំណើរការរួមគ្នានេះមិនមែនជាការងារងាយស្រួលទេ
ដោយសារវាតំរូវឲ្យមានពេលវេលា (ភាពអំណត់) ថវិកា និងធនធានដ៏ទៃទៀត ។ ដោយឡែក
ការកសាងភាពជាដៃគូរក្នុងការរៀបចំនិងអនុវត្តគម្រោងគឺជាការសំខាន់
,ដែលនេះមានន័យថាដំណើរការទាំងឡាយដែលមានពាក់ពន្ធ័គួរតែត្រូវបានយកមកពិចារណា
នៅពេលការបំបែកការងារ និងការចំណាយនិងពេលវេលាដើម្បីរៀបចំគម្រោង ។

**ការវិភាគអ្នកចូលរួមគម្រោង**

អ្នកចូលរួមរួមមានអ្នកទាំងឡាយដែលទទួលឥទ្ធិពលពីសមិទ្ធផលគម្រោង មិនគិតអវិជ្ជមាន
ឬវិជ្ជមាន
និងជនទាំងនោះអាចធ្វើអោយមានផលប៉ះពាល់ទៅដល់លទ្ធផលការអន្តរាគមន៍ដែលបានស្នើរ
សុំ។គំរោងអភិវឌ្ឍន៍ជាធម្មតាកំណត់អត្តសញ្ញាណអ្នកចូលរួមពីរប្រភេទ៖
Primary stakeholder & secondary stakeholder , primary stakeholder
គឺជាក្រុមមនុស្សដែលបានទទួលរងផលប៉ះពាល់ពីគម្រោងយ៉ាងខ្ពស់។secondary stakeholder
គឺក្នុងដំណើរការផ្តល់សេវាទៅអោយ primary stakeholder
បន្ថែមទៀតគឺមានអ្នកចូលរួមខាងក្រៅដែលមានការពាក់ព័ន្ធជាផ្លូវការក្នុងគម្រោង
ប៉ុន្តែជនទាំងនោះអាចមានផលប៉ះពាល់ រឺ រងផលប៉ះពាល់ពីសកម្មភាពគម្រោង។

ធនាគាពិភពលោកបានកំណត់ខ្សែរបន្ទាត់នូវគំរោងសំនួរណែនាំខាងក្រោមដើម្បីជួយធ្វើ
ការកំណត់អត្តសញ្ញាណអ្នកចូលរួមគម្រោងសំខាន់ៗ៖

.អ្នកណាមានឥទ្ធិពល(វិជ្ជមាន រឺ អវិជ្ជមាន) ទាក់ទងនិងការអភិវឌ្ឍន៏ទីតាំង

.អ្នកដែលមិននិយាយតែខំប្រឹងក្នុងការបង្កើត

.អ្នកណាតំណាងអោយអ្នកដែលឥទ្ធិពលដ៏សមគួរនោះ

.អ្នកដែលសមគួរក្នុងការប្រមូលសំរាប់ការប្រឆាំង រឺ ការបំរុងទុក

.អ្នកណាដែលអាចបង្កើតអនាគតដែលមានផលច្រើនទៅលើអ្នកដែលចូលរួមតិចតួច និងសំរាប់អ្នកមិនចូលរួម រឺភាពផ្ទុយទាំងស្រុង

.អ្នកណាដែលផ្តល់ហិរញ្ញវត្ថុ និង ធនធានបច្ចេកទេស

.ឥរិយាបទរបស់អ្នកណា ដែលមានការផ្លាស់ប្តូរសំរាប់ការប្រឹងប្រែងដ៏ជោគជ័យ

ការវិភាគសមាជិកគឺប្រើប្រាស់ការកំនត់ទាំងអស់របស់ក្រុម និងអ្នកដទៃផ្សេងពីគ្នា ដែលមានបង្គោល រឺការចាប់អារម្មណ៏នៅក្នុង ការជោគជ័យ រឺមិនជោគជ័យ របស់សកម្មភាពគំរោង

LFA មួយណាដែលត្រូវពិភាក្សានៅផ្នែកបន្ទាប់ ប្រើការវិភាគសមាជិកនៅក្នុងការបញ្ចូលសមាជិកបន្តបន្ទាប់នៃគម្រោង

មានសមាជិកជាច្រើនក្នុងការអភិវឌ្ឍន៏គម្រោង ម្នាក់ក្នុងចំណោមអ្នកសំខាន់គឺ ៖ ម្ចាស់គម្រោង ,អ្នកផ្តល់ទុនគម្រោង ,គម្រោង គាំទ្រ ,អ្នកគ្រប់គ្រងគម្រោង ,ក្រុមគម្រោង និងអ្នកដែលមានឥទ្ធិពល

**2.3 ម្ចាស់គម្រោង**

វាចាំបាច់សំរាប់ការកំនត់ម្ចាស់កម្មសិទ្ធិ នៅក្នុងការអភិវឌ្ឍន៏គម្រោង ពីព្រោះការកំណត់តំណែង ,ច្បាប់ និង រចនាសម្ព័ន្ធសំរាប់គម្រោង ,គឺការកំណត់នូវម្ចាស់នៃការបង្កើតគំនិតដែលអះអាងថាត្រូវការ ,key parameters ,តំបន់នៃសង្គម ព្រឹត្តការណ៏នៃវប្បធម៏ គឺការគិត

អ្វីជា 'ownership' ក្នុងបរិបទ ICTD?

Siochru និង girard សំដៅលើ ownership ឬ taking ownership គឺ "ដំណើរនៃពេល នៃការទទួលខុសត្រូវ សំរាប់ដំណើរការ ការអភិវឌ្ឍន៏ និងវាជាលទ្ធផល ,ទោះជា willingness ខំប្រឹងវិនិយោគសន្ទឹកសន្ធាប់ និង ធនធាន ,វាជាទូទៅយល់ឃើញថាអ្វីៗដែលត្រូវការជាមុន សំរាប់ជួយគាំទ្រ ទៅលើសកម្មភាពគម្រោង

នៅក្នុងតំបន់ខ្លះ 'អតិថិជន' 'end-user' និង'owner' ជាវេវចនៈ នេះជាបុគ្គលឬអង្គភាពដែលនិងប្រើប្រាស់ផលិតផលគម្រោង ,យោងតាម Wikipedia សេដ្ឋកិច្ច និងនិយមន័យនៃជំនួញ សំរាប់ end-user ជា "បុគ្គល (ក្រុម ,អង្គភាព) អ្នកដែលប្រើប្រាស់ផលិតផល" ទោះជាយ៉ាងណា end-user និង អតិថិជនអ្នកប្រើប្រាស់ គឺមានភាពខុសប្លែកពីគ្នា " អ្នកដែលទិញផលិតផល ប៉ុន្តែ មិនមែនយកទៅប្រើប្រាស់ "

ដូចគ្នាទៅនឹងធនធានដែលសំដៅទៅលើ end-user ក្នុងការទទួលយកនូវ software engineering ដែលសំដៅទៅលើ "an abstraction ក្រុមនៃបុគ្គល ( គោលដៅអ្នកប្រើប្រាស់ ឬ ការរំពឹងទុកនៃអ្នកប្រើប្រាស់ )តើអ្នកណានៅទីបំផុតធ្វើការបែងចែកនូវ software"

នៅក្នុងគម្រោង e-government ម្ចាស់គម្រោងគឺជាការប្រព្រឹត្តនៅអង្គភាព ឧ. បុគ្គលនៅក្នុងសហគ្រាសអ្នកណាដែលគ្របដណ្តប់ផ្ទាល់ភាគច្រើន និង ដឹកនាំក្នុងការបំពេញកិច្ចការគម្រោង ម្ចាស់គម្រោងត្រូវកំណត់ការបញ្ចប់ 'អ្នកប្រើ' នៃអ្នកបង្កើតគំនិត ,រួមបញ្ចូលនិងអ្នកប្រើប្រាស់ដែលអាចជាក្រុមនៃរដ្ឋាភិបាលជាតិ ឬ រដ្ឋាភិបាលតំបន់ ,សហគមន៍ ,សហគមន៍ ឬ សហគ្រាសដែលមិនរកប្រាក់ចំណេញ ការសំរេច ,សមត្ថភាព និង ការជួយគាំទ្រនៃគម្រោងដោយពឹងទៅលើគំរោង 'ការសំរេចិត្តនៃអ្នកដែលជាម្ចាស់ និង អ្នកប្រើប្រាស់ '

**2.4 អ្នកផ្តល់ទុនគម្រោង និង អ្នកផ្តល់អោយ**

